សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការប្រៀបធៀបបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្ត

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ ៖
និស្សិតឈ្មោះ **ឡឹង រាជា**
**ម៉ិច ពៅ**
ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២០

សាស្ត្រាចារ្យណែនាំ ៖
លោក **ម៉ម ចាន់ណែត**
ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# សេចក្តីធានាអះអាង

6

ខ្ញុំបាទឈ្មោះ **ឡឹង រាជា** ជាអក្សរឡាតាំង **LOENG REACHEA** កើតនៅថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ១៩៩៨ មានស្រុកកំណើតនៅភូមិរលួស ឃុំក្រាំងអំពិល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ បច្ចុប្បន្នជានិស្សិតឆ្នាំទី ៤ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាបេក្ខភាពការពារសារណា សម្រាប់ឆ្នាំសិក្សា ២០១៩-២០២០។

ខ្ញុំបាទឈ្មោះ **ពិច ពៅ** ជាអក្សរឡាតាំង **PICH POV** កើតនៅថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ១៩៩៨ មានស្រុកកំណើតនៅភូមិស៊ីធរលិច ឃុំស៊ីធរ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល បច្ចុប្បន្នជានិស្សិតឆ្នាំទី ៤ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាបេក្ខភាពការពារសារណា សម្រាប់ឆ្នាំសិក្សា ២០១៩-២០២០។

យើងខ្ញុំសូមធានាអះអាងថា ខ្លឹមសារនៃសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រដែលមានប្រធានបទ ការប្រៀបធៀបបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្ត មួយនេះពុំមានជាប់ទាក់ទងទៅនឹងខ្លឹមសារសារណា របស់អ្នកណាផ្សេងឡើយ ពោលគឺជាស្នាដៃកើតចេញពីការខិតខំប្រឹងប្រែងសិក្សាស្រាវជ្រាវរបស់យើងខ្ញុំ និងតាមរយៈការណែនាំ និងចង្អុលបង្ហាញរបស់សាស្ត្រាចារ្យ។ គ្មានផ្នែកណាមួយនៃសារណាមួយនេះ ត្រូវបានដកស្រង់មកដោយមិនបានបង្ហាញអំពីប្រភព និងស្នាដៃរបស់អ្នកនិពន្ធ ឬអ្នករៀបរៀងណាមួយនោះទេ។

យើងខ្ញុំនឹងទទួលខុសត្រូវចំពោះច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ប្រសិនបើសារណាមួយនេះបានលួចចម្លងចេញពីឯកសាររបស់អ្នកដទៃ ដែលធ្វើឱ្យប៉ះពាល់ដល់កម្មសិទ្ធិបញ្ញានោះ។

# សេចក្តីថ្លែងអំណរគុណ

6

ជាដំបូងក្នុងនាមយើងខ្ញុំឈ្មោះ **ឡឹង រាជា** និង **ម៉ិច ពៅ** ដែលជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនិតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី ២០ ឆ្នាំសិក្សា ២០១៦-២០២០ សូមសម្តែងនូវការដឹងគុណយ៉ាងក្រៃលែងចំពោះ**លោកឪពុក** និង**អ្នកម្តាយ** ដែលបានចិញ្ចឹម បីបាច់ ថែរក្សាកូនតាំងពីតូចរហូតមក។ មិនត្រឹមតែប៉ុណ្ណោះថែមទាំង អប់ រំទូន្មានប្រៀនប្រដៅ និងបានបញ្ជូនកូនឱ្យទៅសិក្សានៅសាលារៀន ដើម្បីទទួលបាននូវចំណេះដឹងបន្ថែមក្នុងការរៀបចំខ្លួនឱ្យក្លាយទៅជា កូនល្អ សិស្សល្អ និងមិត្តល្អ ដែលសង្គមជាតិទទួលស្គាល់ថាជាមនុស្សប្រកបទៅដោយសេចក្តីថ្លៃថ្នូរ។ ជាងនេះទៅទៀត លោកទាំងពីរតែងតែបានជួយទំនុបបម្រុងកូននៅក្នុងការសិក្សា និងលើកទឹកចិត្តឱ្យកូនខិតខំរៀនសូត្រ ដើម្បីអនាគតខ្លួនឯង និងប្រទេសជាតិ។ តាមរយៈអំពើល្អទាំងអស់នេះ កូនសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោកតាមជួយគ្រងថែរក្សា លោកឪពុក អ្នកម្តាយ ឱ្យជួបប្រទះតែសេចក្តីសុខ និងសេចក្តីចម្រើន លើពីនេះទៅទៀតសូមឱ្យលោកទាំងពីរជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាតឡើយ។

ជាបន្តទៀតនេះ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ៖

- ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។
- ឯកឧត្តមបណ្ឌិត **លុយ ចន្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- លោកគ្រូសាស្ត្រាចារ្យ **ញឹក ឧុទ្ធី** ប្រធានការិយាល័យស្រាវជ្រាវ រួមទាំងបុគ្គលិកដែលបម្រើការនៅក្នុងការិយាល័យស្រាវជ្រាវ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- លោកគ្រូ អ្នកគ្រូនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលធ្លាប់បានបង្ហាត់បង្រៀនយើងខ្ញុំកន្លងមក ក្នុងរយៈពេល បួន ឆ្នាំមកនេះ។
- មិត្តភក្តិរួមជំនាន់ ព្រមទាំងសិស្សច្បងជំនាន់មុនដែលបានផ្តល់នូវមតិយោបល់នៅក្នុងការកែលម្អសារណាមួយនេះ និងថែមទាំងបានជួយសម្រួលដល់ដំណើរការ ក្នុងការចងក្រងសារណាមួយនេះ។
- លោកគ្រូសាស្ត្រាចារ្យ **ម៉ម ចាន់ណែត** សាស្ត្រាចារ្យណែនាំ ដែលលោកបានចំណាយពេលវេលាដល់មានតម្លៃ មកពន្យល់ណែនាំ កែតម្រូវ និងបានផ្តល់នូវមូលវិចារណ៍ដ៏មានតម្លៃ ដើម្បីឱ្យសារណាមួយនេះ បានចេញជារូបរាងឡើង។

# អារម្ភកថា

6

ជាដំបូងក្នុងនាមយើងខ្ញុំជានិស្សិតឆ្នាំទី ៤ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មានសេចក្តីសោមនស្សរីករាយ និងសូមថ្លែងអំណរគុណចំពោះលោកគ្រូអ្នកគ្រូសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យ ជាពិសេសលោកគ្រូសាស្ត្រាចារ្យ **ម៉ម ចាន់ណៃត** ដែលបានបង្ហាត់បង្រៀន និងណែនាំចង្អុលបង្ហាញមកកាន់យើងខ្ញុំ មិនត្រឹមតែប៉ុណ្ណោះថែមទាំងបានចែករំលែកនូវចំណេះដឹងមួយចំនួន ជាបច្ច័យដើម្បីទទួលបានការស្រាវជ្រាវ និងចងក្រងជាសារណាដែលទាក់ទងនឹងប្រធានបទ **ការប្រៀបធៀបបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្ត**។ ទន្ទឹមនឹងនោះដើម្បីឱ្យកិច្ចការស្រាវជ្រាវប្រព្រឹត្តទៅបានល្អ យើងខ្ញុំដែលជានិស្សិត បានរួមគ្នាខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តក្នុងការស្វែងរក ឯកសារទាក់ទង និងមានអត្ថន័យយកមករួមបញ្ចូលគ្នា ឲ្យកាន់តែមានខ្លឹមសារសមស្របទៅនឹងប្រធានបទ។

នៅក្នុងការសិក្សាលើប្រធានបទនេះ យើងខ្ញុំបានធ្វើការសិក្សាដោយយកចិត្តទុកដាក់ក្នុងការស្វែងរកឯកសារដែលពាក់ព័ន្ធ។ ការស្រាវជ្រាវមួយនេះពឹងផ្អែកទៅលើឯកសារគតិយុត្តមួយចំនួនដូចជារដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ ១៩៩៣) ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ ២០០៩) ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាសម័យអន្តរកាលក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធមួយចំនួនទៀត។

ជាចុងក្រោយ យើងខ្ញុំសង្ឃឹមថាស្នាដៃមួយនេះនឹងបម្រើដល់សេចក្តីត្រូវការរបស់អ្នកសិក្សាផ្នែកច្បាប់ទាំងឡាយ ឬអ្នកដែលចង់ស្វែងយល់នូវចំណុចមួយចំនួនដែលទាក់ទងនឹងប្រធានបទ ។ ម្យ៉ាងវិញទៀតយើងខ្ញុំសូមទទួលយកមតិរិះគន់ក្នុងន័យស្ថាបនាគ្រប់មជ្ឈដ្ឋានទាំងអស់ ដើម្បីជាបច្ច័យក្នុងការកែលម្អនូវប្រធានបទមួយនេះឱ្យកាន់តែមានខ្លឹមសារថែមមួយកម្រិតទៀត។

## មាតិកា

ទំព័រ

### សេចក្តីផ្តើម


**១. លំនាំបញ្ហានៃការស្រាវជ្រាវ**......១
**២. ចំណោទបញ្ហានៃការស្រាវជ្រាវ**......១
**៣. គោលបំណងនៃការស្រាវជ្រាវ**......២
**៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ**......២
**៥. សារៈសំខាន់នៃការស្រាវជ្រាវ**......២
**៦. វិធីសាស្ត្រនៃការស្រាវជ្រាវ**......២
**៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ**......៣


### ជំពូកទី ១ បទល្មើសឆបោក


**១.១ ធាតុផ្សំនីត្យានុកូល**......៤
១.១.១ ស្ថានទម្ងន់ទោស......៤
១.១.២ ទោសបន្ថែម......១០
**១.២ ធាតុផ្សំសត្យានុម័ត**......១០
១.២.១ មូលនិធិ តម្លៃ និងទ្រព្យសម្បត្តិ......១១
១.២.២ ការប្រើឈ្មោះក្លែង......១១
១.២.៣ ការអះអាងលើឋានៈក្លែង......១១
១.២.៤ ការរំលោភលើឋានៈពិតប្រាកដ......១១
១.២.៥ ការប្រើឧបាយកលទុច្ចរិត......១១
១.២.៦ ការប៉ុនប៉ងក្នុងបទល្មើសឆបោក......១២
១.២.៧ បទល្មើសប្រហាក់ប្រហែលនឹងបទល្មើសឆបោក......១២
**១.៣ ធាតុផ្សំអត្តនោម័ត**......១៤


### ជំពូកទី ២ បទល្មើសរំលោភលើទំនុកចិត្ត


**២.១ ធាតុផ្សំនីត្យានុកូល**......១៥
២.១.១ ស្ថានទម្ងន់ទោស......១៥
២.១.២ ទោសបន្ថែម......១៦
**២.២ ធាតុផ្សំសត្យានុម័ត**......១៧
២.២.១ មូលនិធិ តម្លៃ និងទ្រព្យសម្បត្តិ......១៧
២.២.២ ការគេចបំបាត់......១៧
២.២.៣ ការប្រគល់ឱ្យនូវមូលនិធិ តម្លៃ និងទ្រព្យសម្បត្តិ......១៨

២.២.៤ ការប្រើប្រាស់ជាកំណត់ ........ ១៩
២.២.៥ ការប៉ុនប៉ង ........ ២០
២.២.៦ បទរំលោភលើទំនុកចិត្តពិសេស ........ ២០
២.២.៧ បទល្មើសប្រហាក់ប្រហែលនឹងបទល្មើសរំលោភលើទំនុកចិត្ត ........ ២១
**២.៣ ធាតុផ្សំអត្តនោម័ត** ........ ២២
២.៣.១ ចេតនាទុច្ចរិតទូទៅ ........ ២២
២.៣.២ ចេតនាទុច្ចរិតពិសេស ........ ២២
**ជំពូកទី ៣ ការប្រៀបធៀបបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្ត**
**៣.១ ចំណុចដូចគ្នា** ........ ២៤
**៣.១.១ ធាតុផ្សំនីត្យានុកូល** ........ ២៤
៣.១.១.១ ការចែងក្នុងគន្ថី ........ ២៤
៣.១.១.២ ការចែងក្នុងមាតិកា ........ ២៤
៣.១.១.៣ នីត្យានុកូលភាពនៃទោស ........ ២៤
៣.១.១.៤ ការប៉ុនប៉ង ........ ២៥
**៣.១.២ ប្រធាននៃបទល្មើស** ........ ២៥
៣.១.២.១ ជនរងគ្រោះ ........ ២៥
៣.១.២.២ ជនល្មើស ........ ២៥
**៣.១.៣ ព្យសនកម្ម** ........ ២៦
**៣.១.៤ ចំណាត់ថ្នាក់នៃបទល្មើស** ........ ២៦
**៣.១.៥ អាជ្ញាយុកាល** ........ ២៧
**៣.២. ចំណុចខុសគ្នា** ........ ២៧
**៣.២.១ ធាតុនីត្យានុកូល** ........ ២៧
៣.២.១.១ នីត្យានុកូលភាពនៃបទល្មើស ........ ២៨
៣.២.១.២ ការចែងក្នុងជំពូក ........ ២៨
៣.២.១.៣ ស្ថានទម្ងន់ទោស ........ ២៩
៣.២.១.៤ ទោសបន្ថែម ........ ៣០
**៣.២.២ ធាតុសត្យានុម័ត** ........ ៣១
៣.២.២.១ រូបរាងនៃអំពើ ........ ៣១
៣.២.២.២ លក្ខណៈនៃអំពើ ........ ៣២
៣.២.២.៣ កម្មវត្ថុនៃបទល្មើស ........ ៣៣
**៣.២.៣ ធាតុអត្តនោម័ត** ........ ៣៣
**៣.៣ ករណីសិក្សា** ........ ៣៤

**សេចក្តីសន្និដ្ឋាន** ........................................................................................ ៣៨
**អនុសាសន៍** ........................................................................................ ៤០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងប្រទេសកម្ពុជា ឃើញថាមានលិខិតបទដ្ឋានគតិយុត្តជាច្រើនដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីរៀបចំ និងរបៀបរៀបរយនៅក្នុងប្រទេសឱ្យប្រកបទៅរកភាពសុខដុមរម្យនា។ ជាក់ស្តែងនៅថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានចូលជាធរមានដែលនៅក្នុងនោះបានបែងចែកជា ៦ គន្ថី ហើយបានកំណត់អំពីគោលការណ៍ទូទៅ និងបទល្មើសធំៗមួយចំនួនទៀតដូចជា បទល្មើសប្រឆាំងបុគ្គល បទល្មើសប្រឆាំងទ្រព្យសម្បត្តិ និងបទល្មើសប្រឆាំងនឹងជាតិ។

ចំពោះគន្ថីដែលបានចែងអំពីបទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ ដែលបានកំណត់នូវបទល្មើសជាច្រើន ដែលតម្រូវឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌ។ ជាពិសេស មានបទល្មើសពីរដែលបានកំណត់នៅក្នុងបទល្មើសនេះផងដែរ គឺបទល្មើសឆបោក និងរំលោភលើទំនុកចិត្ត ហើយដែលបទល្មើសទាំងនេះបានបណ្តាលឱ្យមានការប៉ះពាល់ដល់បុគ្គលដទៃ។

នៅក្នុងសារណារបស់យើងខ្ញុំនេះ បានលើកយកនូវបទល្មើសពីរគឺបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្ត សម្រាប់យកមកធ្វើការបកស្រាយឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀត។ អំពើឆបោកនេះមិនត្រឹមតែបានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ នេះទេ ពោលគឺមានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌអន្តរកាលផងដែរ។ នៅក្នុងក្រមព្រហ្មទណ្ឌបច្ចុប្បន្ន យើងអាចមើលឃើញនៅក្នុងមាត្រា ៣៧៧ បានកំណត់ថាជា ការឆបោក ចំណែកឯច្បាប់ព្រហ្មទណ្ឌអន្តរកាលវិញនៅក្នុងមាត្រា ៤៥ បានកំណត់ថាជាអំពើឆបោក តែបើយើងពិនិត្យមើលទៅលើច្បាប់ អេង សុត មាត្រា ៥១៥ ដែលត្រូវបានប្រើប្រាស់នៅក្នុងទស្សវត្សរ៍ទី ៦០ វិញយើងឃើញត្រឹមតែពាក្យ ឆបោក ប៉ុណ្ណោះ។ ដោយឡែកនៅក្នុងបទល្មើសរំលោភលើទំនុកចិត្តវិញ បើពិនិត្យមើលទៅលើក្រមព្រហ្មទណ្ឌបច្ចុប្បន្ន ឆ្នាំ ២០០៩ មាត្រា ៣៩១ បានកំណត់ថាជាការរំលោភលើទំនុកចិត្ត ចំណែកឯច្បាប់ព្រហ្មទណ្ឌអន្តរកាលវិញគឺបានកំណត់ថាជា ការរំលោភលើសេចក្តីទុកចិត្ត ប៉ុន្តែបើយើងពិនិត្យមើលទៅលើមាត្រា ៥១៥ នៃច្បាប់ អេង សុត វិញឃើញថាមានកំណត់ត្រឹមតែពាក្យ រំលោភលើទំនុកចិត្តប៉ុណ្ណោះ។ ទោះបីយ៉ាងណាក៏ដោយ នៅក្នុងបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្ត គឺមានលក្ខណៈស្រដៀងគ្នា ដែលបណ្តាលឱ្យអ្នកសិក្សាមួយចំនួនមានការយល់ច្រឡំចំពោះសញ្ញាណផ្សេងៗនៅក្នុងបទល្មើសទាំងពីរនេះ។ ហេតុដូចច្នេះហើយបានជាយើងខ្ញុំ បានធ្វើការចងក្រងនូវឯកសារមួយនេះឡើងដើម្បីទុកជាទុនមួយសម្រាប់អ្នកសិក្សាផ្នែកច្បាប់ទាំងអស់ បានស្វែងយល់បន្ថែមកុំឱ្យមានការយល់ច្រឡំចំពោះបទល្មើសទាំងពីរនេះ។

ស្ថិតក្រោមមូលហេតុនេះហើយបានជាយើងខ្ញុំធ្វើការរៀបចំ និងតាក់តែងនូវសារណានេះឡើង ដែលមានចំណងជើងថា **ការប្រៀបធៀបបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្ត**។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ចំណុចដែលយើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវដោយផ្អែកទៅលើចំណោទមួយចំនួនដែលទាក់ទងទៅនឹង អត្ថន័យនៃបទល្មើស និងការប្រៀបធៀបលក្ខណៈដូចគ្នា និងខុសគ្នា។ យើងខ្ញុំសូមលើកយកនូវចំណោទបញ្ហាមួយចំនួនដូចជា ៖

-តើអ្វីទៅជាបទល្មើសឆបោក? ហើយមានលក្ខណៈពិសេសអ្វីខ្លះ?

-តើបទល្មើសរំលោភលើទំនុកចិត្តមានលក្ខណៈយ៉ាងដូចម្តេច?

-តើបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្តមានលក្ខណៈដូចគ្នា និងខុសគ្នាយ៉ាងដូចម្តេច?

## ៣.គោលបំណងនៃការស្រាវជ្រាវ

ការសម្រេចចិត្តជ្រើសរើសយកប្រធានបទនេះមកសរសេរជាសារណា ដោយសារតែយើងខ្ញុំយល់ឃើញថា ប្រធានបទនេះមានសារៈសំខាន់សម្រាប់សង្គមយើងបច្ចុប្បន្ន ទាំងទ្រឹស្តី និងការអនុវត្ត។ ម្យ៉ាងវិញទៀតកម្មវត្ថុនៃការស្រាវជ្រាវនឹងត្រូវបានបង្ហាញដូចខាងក្រោម ៖

-ស្វែងយល់អំពីលក្ខណៈនៃបទល្មើសឆបោក ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ចាប់ពីមាត្រា ៣៧៧ ដល់មាត្រា ៣៨២។

-ស្វែងយល់អំពីលក្ខណៈនៃបទល្មើសរំលោភលើទំនុកចិត្ត ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ចាប់ពីមាត្រា ៣៩១ ដល់មាត្រា ៣៩៦។

-ធ្វើការប្រៀបធៀបបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្ត រួចទាញរកលក្ខណៈដូចគ្នា និងលក្ខណៈខុសគ្នា។

-បង្ហាញអំពីករណីសិក្សាមួយចំនួនដែលទាក់ទងបទល្មើសទាំងពីរ។

-ធ្វើសេចក្តីសន្និដ្ឋាន និងអនុសាសន៍ ដើម្បីរួមចំណែកនៅក្នុងការកែលម្អ។

## ៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវទៅលើប្រធានបទនេះយើងខ្ញុំធ្វើការសិក្សាទៅលើតែច្បាប់ព្រហ្មទណ្ឌពេលបច្ចុប្បន្ន ឆ្នាំ ២០០៩ ប៉ុណ្ណោះ ហើយម្យ៉ាងវិញទៀត យើងខ្ញុំនឹងធ្វើការសង្កត់ធ្ងន់ទៅលើលក្ខណៈផ្ទាល់នៃប្រធានបទដូចជា និយមន័យ ធាតុផ្សំនៃបទល្មើសនីមួយៗ ទោសដែលត្រូវអនុវត្ត និងការប្រៀបធៀបបទល្មើសទាំងពីរ ដោយបញ្ចូលទាំងចំណុចដូចគ្នា និងចំណុចខុសគ្នា។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់នៃការស្រាវជ្រាវលើប្រធានបទមួយនេះមានដូចជា ៖

-ពង្រីក និងបង្កើននូវចំណេះដឹងទៅលើបទល្មើសដែលមានលក្ខណៈស្រដៀងគ្នា ដែលធ្វើឱ្យមានភាពលំបាកនៅក្នុងការវិភាគ ព្រមទាំងវែកញែកបទល្មើសឱ្យដាច់ចេញពីគ្នា

-បង្កើតចំណេះដឹងបន្ថែមលើផ្នែកព្រហ្មទណ្ឌ ជាពិសេសទៅលើបទល្មើសដែលបានបកស្រាយ

-បង្កើនចំណេះដឹងក្នុងការប្រៀបធៀប និងវែកញែកអំពីភាពខុសគ្នានៃបទល្មើសនីមួយៗ

-ជាឯកសារបន្ថែមមួយនៅក្នុងការស្វែងយល់អំពីភាពខុសគ្នានៃបទល្មើសសម្រាប់សាធារណៈជន និងនិស្សិតជំនាន់ក្រោយ

-ជាឯកសារជំនួយមួយនៅក្នុងការប្រៀបធៀបបទល្មើសនានា។

## ៦.វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីប្រសិទ្ធភាពនៃសារណាមួយ យើងខ្ញុំបានសិក្សាទៅលើឯកសារជាច្រើនដែលពាក់ព័ន្ធ ដែលឯកសារទាំងនោះមានឯកសារចម្បង និងឯកសារបន្ទាប់បន្សំ ដែលឯកសារទាំងនោះត្រូវបានដកស្រង់

ចេញពី បណ្ណាល័យ មូលវិចារណ៍របស់សាស្ត្រចារ្យនានា និងដកស្រង់ចេញពីប្រព័ន្ធអ៊ីនធើណេតផ្សេងៗ។

**ឯកសារចម្បង ៖**

-រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

-ច្បាប់ព្រហ្មទណ្ឌអន្តរកាល

-ក្រមនីតិវិធីព្រហ្មទណ្ឌ

**ឯកសារបន្ទាប់បន្សំ ៖**

-ឯកសារមេរៀនដែលបានមកពីការបង្រៀនរបស់សាស្ត្រចារ្យផ្សេងៗ

-ឯកសារដែលបានមកពីសៀវភៅព្រហ្មទណ្ឌពិសេស និងព្រហ្មទណ្ឌទូទៅ

-ឯកសារដែលបានមកពីប្រព័ន្ធអ៊ីធើណេត

-ឯកសារដែលបានមកពីការចង្អុលបង្ហាញរបស់សាស្ត្រាចារ្យណែនាំ

-ឯកសារដែលបានមកពីនិស្សិតជំនាន់មុនៗ។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងសារណានេះ ត្រូវបានចែកចេញជា ៣ ជំពូក ៖ ជំពូកទី ១ បទល្មើសឆបោក ជំពូកទី២ បទល្មើសរំលោភលើទំនុកចិត្ត និងជំពូកទី ៣ ការប្រៀបធៀបបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្ត។

# ជំពូកទី១ ៖ បទល្មើសឆបោក

## ១.១ ធាតុផ្សំនីត្យានុកូល

ដោយយោងទៅតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន[1] ឆ្នាំ ២០០៩ បានកំណត់ថា អំពើឆបោក គឺជាអំពើបន្លំចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយ ដោយប្រើឈ្មោះក្លែងដោយអះអាងទៅលើឋានៈក្លែង ដោយរំលោភលើឋានៈពិតប្រាកដ ឬដោយប្រើឧបាយកលទុច្ចរិត ហើយដូច្នេះបានទទួលពីបុគ្គលនេះ ដែលនាំឱ្យខូចប្រយោជន៍ដល់បុគ្គលនេះ ឬរបស់តតិយជននូវៈ

-ការប្រគល់នូវមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ។

-ការផ្គត់ផ្គង់សេវា។

-ការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬជាការឱ្យរួចផុតពីកាតព្វកិច្ច។

អំពើឆបោក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល។

ដោយឡែកបើយើងពិនិត្យមើលទៅលើ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ឆ្នាំ ១៩៩២ នៅក្នុងមាត្រា ៤៥ វិញ អំពើឆបោកសំដៅដល់ ជនណាដែលធ្វើឱ្យគេឱ្យមកខ្លួន ឬប៉ុនប៉ងធ្វើឱ្យគេឱ្យមកខ្លួននូវទ្រព្យសម្បត្តិទាំងអស់ ឬមួយចំណែកនៃទ្រព្យសម្បត្តិរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដោយប្រើល្បិចបន្លំ ឬក្លែងឈ្មោះ ឬក្លែងគុណភាព ដើម្បីបញ្ចុះបញ្ចូលជនរងគ្រោះឱ្យជឿតាមអំណាចនៃការស្រម៉ៃ ឬដោយធ្វើឱ្យជនរងគ្រោះខ្លាច ឬសង្ឃឹមលើព្រឹត្តិការណ៍អ្វីមួយ។ ចំពោះការផ្តន្ទាទោសវិញ គឺត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ។

មួយវិញទៀត បើយើងក្រឡេកទៅមើលច្បាប់ព្រហ្មទណ្ឌអន្តរកាលនៅក្នុង ឆ្នាំ ១៩៦៤ មួយទៀត ដែលនៅក្នុងនោះ ត្រង់មាត្រា ៥១៥ បានកំណត់ថា ឆបោក គឺជាកិរិយាប្រើឧបាយកលទុច្ចរិត ដើម្បីញុំាងគេ ឬបំណងនឹងញុំាងគេឱ្យប្រគល់ទ្រព្យគេទាំងអស់ ឬខ្លះមកឱ្យខ្លួន។

### ១.១.១ ស្ថានទម្ងន់ទោស

ការមិនរាងចាលក៏ត្រូវបានចាត់ទុកថាជាស្ថានទម្ងន់ផងដែរ នេះបើយោងតាមមាត្រា ៨៣ នៃក្រមព្រហ្មទណ្ឌដែលបានបញ្ញត្តថា ការមិនរាងចាលមានអានុភាពនាំឲ្យមានការបន្ថែមទម្ងន់អតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមនៅក្នុងលក្ខខណ្ឌដែលមានចែង។ នេះមានន័យថាកាលបើជនណាម្នាក់បានទទួលនូវសាលក្រមផ្តន្ទាទោសជាស្ថាពរពីតុលាការម្តងរួចហើយ ប៉ុន្តែមិនទាន់ផុតរយៈពេលកំណត់ផងជននោះបានប្រព្រឹត្តនូវបទល្មើសមួយថ្មីទៀត ទើបធ្វើឲ្យតុលាការបន្ថែមនូវទម្ងន់អតិបរមានៃទោសដាក់ពន្ធនាគារទៅលើជននោះ។

**ឧទាហរណ៍** ៖ ក បានប្រព្រឹត្តនូវបទហិង្សាដោយចេតនា ហើយត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារ ២ ឆ្នាំ ប៉ុន្តែមិនទាន់គ្រប់រយៈពេលដែលត្រូវកំណត់ ៥ ឆ្នាំផង ក បានប្រព្រឹត្តល្មើសឆបោកថ្មី

[1] មាត្រា ៣៧៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

ម្តងទៀត។ នោះ ក ត្រូវស្ថិតនៅក្នុងការមិនរាងចាល ដែលធ្វើឱ្យខ្លួនត្រូវបន្ថែមទម្ងន់អតិបរមានៃទោសដាក់ពន្ធនាគារទៅលើបទល្មើសឆបោកថ្មីនោះ។

ប៉ុន្តែស្ថានទម្ងន់ទោសដែលបានកំណត់នៅក្នុងបទល្មើសឆបោកវិញមានពីរគឺ ស្ថានទម្ងន់ទោសដែលទាក់ទងទៅនឹងជនរងគ្រោះ និងស្ថានទម្ងន់ផ្សេងទៀត។

**ស្ថានទម្ងន់ទោសដែលទាក់ទងទៅនឹងជនរងគ្រោះ[2]**

អំពើឆបោក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ កាលបើអំពើនេះបានប្រព្រឹត្តនាំឲ្យខូចប្រយោជន៍ ៖

- បុគ្គលដែលទន់ខ្សោយពិសេស ដោយសារមូលហេតុអាយុនៃបុគ្គលនោះ។
- នារីមានគភ៌ កាលបើមានគភ៌ ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង។
- បុគ្គលដែលទន់ខ្សោយពិសេស ដោយសារមូលហេតុនៃជម្ងឺ ឬពិការភាព កាលបើស្ថានភាពបុគ្គលនោះត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង។

តាមន័យនេះយើងសង្កេតឃើញថា បើទោះបីជាមានស្ថានទម្ងន់ដែលទាក់ទងទៅនឹងជនរងគ្រោះដូចដែលបានកំណត់នៅក្នុងមាត្រា ៣៧៩ ក៏ដោយ ក៏ពុំបានកែប្រែនូវកម្រិតនៃបទល្មើសនោះទេ ពោលគឺស្ថិតនៅក្នុងបទមជ្ឈិមដដែល នេះបើធៀបទៅនឹងមាត្រា ៣៧៨ ទោសដែលត្រូវអនុវត្តចំពោះបទល្មើសឆបោក។

ដើម្បីឱ្យកាន់តែច្បាស់ យើងនឹងសិក្សាទៅលើស្ថានទម្ងន់ទោសនីមួយៗនៅក្នុងចំណុចនេះ ៖

**- បុគ្គលដែលទន់ខ្សោយពិសេស ដោយសារមូលហេតុរបស់បុគ្គលនោះ**

នៅក្នុងការកំណត់ដែលទាក់ទងនឹងបុគ្គលដែលទន់ខ្សោយពិសេស ដោយសារមូលហេតុនៃអាយុនេះ យើងអាចមើលឃើញថា ការកំណត់លើអាយុ អាចជាការសិក្សាទៅលើអនីតិជន និងជនចាស់ជរា។ ប៉ុន្តែយើងមិនអាចកំណត់បានទេថា អនីតិជន ឬជនចាស់ជរានោះ ស្ថិតនៅក្នុងអាយុប៉ុន្មាននោះទេ។

មូលហេតុនៃអាយុមិនអាចបំពេញលក្ខខណ្ឌគ្រប់គ្រាន់នោះទេ ប៉ុន្តែអ្វីដែលសំខាន់គឺផ្អែកលើភាពទន់ខ្សោយរបស់ជនរងគ្រោះ។ នៅក្នុងសង្គមយើងបច្ចុប្បន្ន យើងសង្កេតឃើញថា ទោះបីជាបទល្មើសខ្លះបានប្រព្រឹត្តដោយអនីតិជនក៏ដោយ តែសមត្ថភាព កម្លាំងកាយ មានលក្ខណៈពេញលេញ ដូច្នេះបានសេចក្តីថា គេមិនចាត់ទុកថាជាជនដែលទន់ខ្សោយពិសេសឡើយ។ ដោយឡែក អនីតិជនខ្លះមានសមត្ថភាពទន់ខ្សោយ ដោយសារកំណើត ដែលធ្វើឲ្យបុគ្គលនោះមានសភាព ស្គមស្គាំង ដើរញើរញ័រ ចំណុចនេះទើបបានត្រូវគេចាត់ទុកថា ជាបុគ្គលដែលទន់ខ្សោយពិសេស។

ចំពោះចាស់ជរាវិញ យើងក៏មិនអាចអះអាងទៅលើអាយុរបស់គាត់បានទេ ប៉ុន្តែយើងអាចសិក្សាទៅលើកម្លាំងតបត ចំពោះបទល្មើសដែលបានប្រព្រឹត្តមកលើគាត់។ យើងអាចធ្វើការសន្មតបានថា ចាស់ជរាគឺមានអាយុចាប់ពី ៧៥ ឡើងទៅ ប៉ុន្តែយើងក៏ត្រូវពិចារណាទៅលើភាពជាក់ស្តែងរបស់ជនរងគ្រោះ។

[2] មាត្រា ៣៧៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

**ឧទាហរណ៍** ៖ បុគ្គល ក បានអះអាងថាខ្លួនជាមន្ត្រីធនាគារមកពីភ្នំពេញ តែតាមពិតខ្លួនមិនមែនជាមន្ត្រីធនាគារអ្វីនោះទេ ហើយបុគ្គល ក បានទៅឆបោកលោកតា ចាស់ជរាម្នាក់ដោយប្រើឧបាយកលថាបើដាក់ប្រាក់សន្សំនៅធនាគារខ្លួននៅពេលនេះនឹង ទទួលបានការប្រាក់ខ្ពស់ ហើយអាចដកបានជារៀងរាល់ខែ។ ដោយគិតឃើញថាបើទុកប្រាក់ ចោលវាគ្មានប្រាក់ចំណូល លោកតាក៏បានប្រគល់ប្រាក់ដែលខ្លួនបានសន្សំចំនួន ៥០០ ដុល្លារ ឲ្យទៅ ក ដោយគិតថាខ្លួននឹងទទួលបានការប្រាក់វិញជារៀងរាល់ខែ។ បន្ទាប់ពីបានទទួលប្រាក់ ក បានធ្វើកិច្ចសន្យាក្លែងក្លាយហើយគេចខ្លួនបាត់ទៅ។

ដូច្នេះអំពើរបស់ ក គឺជាបទល្មើសឆបោកមានស្ថានទម្ងន់ទោសដែលបានប្រព្រឹត្តចំពោះបុគ្គលទន់ខ្សោយពិសេស ដោយសារមូលហេតុអាយុរបស់ជនរងគ្រោះ។

**-នារីមានគភ៌ កាលបើគភ៌ត្រូវបានមើលឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង**

នៅក្នុងការប្រព្រឹត្តបទល្មើសឆបោកដោយមានស្ថានទម្ងន់ ទៅលើនារីមានគភ៌ត្រូវបានញែកចេញជាពីរ ករណី ៖

**ករណីទី ១** ៖ ជនល្មើសប្រព្រឹត្តការឆបោកទៅលើស្ត្រីដែលមានផ្ទៃពោះលេចចេញយ៉ាងជាក់ស្តែង ដោយជនដទៃអាចធ្វើការសន្និតយល់ដឹងអំពីការមានផ្ទៃពោះរបស់ស្ត្រីនោះបាន។

**ករណីទី ២** ៖ ជនល្មើសប្រព្រឹត្តការឆបោកទៅលើស្ត្រីមានផ្ទៃពោះ ដោយជននោះបានដឹងច្បាស់អំពីការមានគភ៌របស់ជនរងគ្រោះ ទោះបីការមានគភ៌នោះមិនបានស្តែងចេញមកក្រៅជាក់លាក់ក៏ដោយ។ ដូច្នេះច្បាប់កំណត់ថាជនល្មើសត្រូវបានស្ថានទម្ងន់ ទោស។

**ឧទាហរណ៍** ៖ បុរស **ក** និង **ខ** គឺជាមិត្តនឹងគ្នា។ **ខ** មានប្រពន្ធឈ្មោះ **គ** ដែលកំពុងមានផ្ទៃពោះ ៣ ខែ ហើយ **ក** ក៏បានដឹងរឿងនេះដែរ។ ថ្ងៃមួយ ក បានចាញ់ល្បែងអស់ពីខ្លួន ថែមទាំងធ្លាក់ខ្លួនបញ្ចាំម៉ូតូទៀត ដោយគ្មានប្រាក់លោះវិញ **ក** បែកគំនិតប្រើឧបាយកលឆបោក **គ** ថា **ខ** បានជួបគ្រោះថ្នាក់ចរាចរណ៍ត្រូវការលុយជាបន្ទាន់។ ដោយមានការបារម្ភពីប្តីរបស់ខ្លួន **គ** ក៏បានផ្ញើរប្រាក់ទៅឲ្យ **ក** យ៉ាងប្រញ៉ាប់។ ក្នុងករណីនេះ តើបុរស **ក** ត្រូវជាប់ទោសពីបទអ្វី?

**ដំណោះស្រាយ** ៖ ការដែល **ក** បានធ្វើការឆបោកទៅលើ **គ** ដែលកំពុងមានផ្ទៃពោះនោះ ព្រោះតែខ្លាចប្តីរបស់ខ្លួនមានគ្រោះថ្នាក់ដល់អាយុជីវិត តាមរយៈការប្រើឧបាយកលទុច្ចរិតរបស់ **ក**។ យោងទៅតាមមាត្រា ៣៧៩ នៃក្រមព្រហ្មទណ្ឌ អាចបញ្ជាក់បានថា **ក** បានប្រព្រឹត្តបទល្មើសឆបោកដែលមានស្ថានទម្ងន់ទោស ដោយនាំឱ្យខូចប្រយោជន៍នារីមានគភ៌ ដោយ **ក** បានអះអាងថាប្តីរបស់ **គ** បានជួបគ្រោះថ្នាក់ចរាចរណ៍។ ម្យ៉ាងវិញទៀត **ក** ក៏បានដឹងថា **គ** មានផ្ទៃពោះផងដែរ ទោះបីជាគភ៌របស់ **គ** ទើបតែ ៣ ខែក៏ដោយ។ ដូច្នេះ **ក** ត្រូវចោទប្រកាន់ពីបទឆបោកដោយមានស្ថានទម្ងន់ទោសដែលទាក់ទងនឹងជនរងគ្រោះ (បានប្រព្រឹត្តនាំឱ្យខូចប្រយោជន៍ នារីមានគភ៌ កាលបើគភ៌ត្រូវបានមើលឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង) ដែលអាចត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ។

**-បុគ្គលទន់ខ្សោយពិសេស ដោយសារមូលហេតុជម្ងឺ ឬពិការភាព**

នៅក្នុងក្រមព្រហ្មទណ្ឌមិនបានកំណត់ថា បុគ្គលដែលទន់ខ្សោយពិសេសដោយសារមូលហេតុជំងឺមានប្រភេទជម្ងឺដូចម្តេច ឬស្ថិតក្នុងស្ថានភាពជំងឺបែបណានោះទេ។ នៅក្នុងចំណុចនេះ គឺគេសំដៅទៅលើ

ប្រភេទជម្ងឺដែលមានលក្ខណៈធ្ងន់ធ្ងរ រ៉ាំរ៉ៃ ធ្វើឱ្យជនរងគ្រោះអសមត្ថភាពនៅក្នុងការប្រកបការងារផ្សេងៗ។ លក្ខខណ្ឌនៅក្នុងការអនុវត្ត នូវស្ថានទម្ងន់ទោសនេះទៅលើជនល្មើសបានលុះត្រាតែ ជម្ងឺរបស់ជនល្មើស បានបង្ហាញសញ្ញាណ ចេញមកក្រៅ ឬក៏ជនល្មើសបានដឹងអំពីស្ថានភាពនៃជម្ងឺរបស់ជនរងគ្រោះនោះ។ ដោយឡែក ប្រសិនបើជនល្មើសមិនបានដឹងអំពីស្ថានភាពជម្ងឺរបស់ជនរងគ្រោះទេ យើងមិនអាច យក មាត្រា ៣៧៩ ចំណុចទី ៣ នេះមកអនុវត្តបានទេ។ ម្យ៉ាងទៀត យើងក៏មិនអាចអនុវត្តបាន ផងដែរចំពោះ ជម្ងឺដែលមានលក្ខណៈស្រាលដូចជា ផ្តាសាយ ឬជម្ងឺក្អកជាដើម។

**ឧទាហរណ៍** ៖ ស្ត្រីម្នាក់ឈ្មោះ ក ជាមនុស្សគ្មានមុខរបរពិតប្រាកដទេ។ ថ្ងៃមួយ ក បែកគំនិតដើរ លក់ថ្នាំក្លែងក្លាយ ក៏បានជួបនឹងស្ត្រីចំណាស់ម្នាក់ឈ្មោះ ខ ដែលមានជម្ងឺប្រចាំកាយព្យាបាលមិនជាយូរ មកហើយ ។ ដោយមើលឃើញពីអាការៈនៃជម្ងឺ ក បានអះអាងថាខ្លួនជាអ្នកលក់ថ្នាំព្យាបាលជម្ងឺនេះយូរ មកហើយ ថែមទាំងមានការទទួលស្គាល់ពីក្រសួងសុខាភិបាលទៀតផង។ ក បានប្រើឧបាយកលថាថ្នាំ របស់ខ្លួនបានព្យាបាលមនុស្សជាសះស្បើយច្រើននាក់មកហើយ។ ដោយជឿទុកចិត្តនឹងពាក្យលួងលោម របស់ ក គួបផ្សំនឹងជម្ងឺដែលគ្មានភាពសះស្បើយទៀតនោះ ខ បានទិញថ្នាំនោះនៅក្នុងតម្លៃ ១០០ ដុល្លារ។ បន្ទាប់ពីបានប្រាក់ ក ក៏គេចខ្លួនទៅបាត់ទៅ។ តើនៅក្នុងករណីនេះ ស្ត្រី ក ត្រូវមានបទល្មើសអ្វី?

**ដំណោះស្រាយ** ៖ ស្ត្រីចំណាស់ដែលមានឈ្មោះ ខ មានជម្ងឺប្រចាំកាយព្យាបាលមិនជាយូរមក ហើយ នៅក្នុងពេលដែល ក បានជួបនឹង ខ អាការៈនៃជម្ងឺគឺបានស្តែងជាសញ្ញាចេញមកក្រៅ។ ម្យ៉ាងទៀត ស្ថានភាពជម្ងឺរបស់ ខ ធ្វើឲ្យខ្លួនអសមត្ថភាពក្នុងការស្វែងរកជនល្មើស ក ផងដែរ។ យោងទៅតាមមាត្រា ៣៧៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩ អំពើរបស់ ក គឺជាអំពើឆបោកដែលមានស្ថានទម្ងន់ទោស ហេតុ ដូច្នេះស្ត្រី ក ត្រូវជាប់ពីបទ ឆបោកដោយមានស្ថានទម្ងន់ទោសដែលទាក់ទងនឹងជនរងគ្រោះ។

ករណីពិការភាព គឺជាជនដែលទន់ខ្សោយពិសេស ព្រោះតែជនរងគ្រោះគ្មានអវៈយវៈគ្រប់គ្រាន់ក្នុង ការធ្វើសកម្មភាពផ្សេងៗ ហើយអ្វីដែលពិសេសគឺជនរងគ្រោះគ្មានសមត្ថភាពគ្រប់គ្រាន់នៅក្នុងការស្វែងរក ប្រាក់ចំណូលដើម្បីចិញ្ចឹមជីវិតនោះទេ។ ពិការភាពរបស់ជនរងគ្រោះភាគច្រើនត្រូវបានស្តែងចេញមកក្រៅ ប៉ុន្តែពិការភាពខ្លះមិនបានបង្ហាញសញ្ញាណមកក្រៅទេ ជាក់ស្តែងដូចជាករណី គរថ្លង់ជាដើម។ ចំណុចនេះ ទៀតសោតប្រសិនបើជាជនល្មើសមានគោលបំណងនៅក្នុងការឆបោកនោះ ជនល្មើសអាចដឹងពីពិការ ភាពរបស់ជនរងគ្រោះបានយ៉ាងច្បាស់។

ពិការភាពនេះត្រូវពិនិត្យមើលទៅលើស្ថានភាពរបស់បុគ្គលនីមួយៗ ដោយសង្កត់ធ្ងន់ទៅលើសមត្ថ ភាព ឬលទ្ធភាពនៅក្នុងការស្វែងរកប្រាក់ចំណូល។ យើងអាចសិក្សាទៅលើចំណុចធំៗ គឺ ៖

ពិការភាព ជាមូលហេតុដែលធ្វើឲ្យជនរងគ្រោះទន់ខ្សោយពិសេស ៖ បុគ្គលដែលជាជនរងគ្រោះ អាចពិការអវៈយវៈណាមួយរបស់គាត់ ហើយភាពពិការនេះធ្វើឱ្យគាត់ខ្វះខាតនូវកម្លាំងដើម្បីស្វែងរកប្រាក់ ចំណូលដើម្បីទ្រទ្រង់ជីវភាពប្រចាំថ្ងៃ។ ហេតុដូច្នេះហើយបានជាគេសន្មតថាជាភាពទន់ខ្សោយពិសេស។

**ឧទាហរណ៍** ៖ ស្ត្រីម្នាក់ឈ្មោះ ក ពិការជើងម្ខាងធ្ងន់ធ្ងរមិនអាចប្រកបមុខរបរអ្វីបាន។ រាល់ថ្ងៃពឹង លើកូនស្រីដែលលក់បន្លែបន្តិចបន្តួចនៅឯផ្សារ។ ថ្ងៃមួយ ខ បានទៅជួបនឹង ក ហើយអះអាងថាខ្លួនជា ប្រធានអង្គការមួយដែលជួយផ្តល់ថវិកាជាប្រៀងរាល់ខែដល់ជនពិការ ប៉ុន្តែតាមពិត ខ មិនមែនជាប្រធានអង្គ

ការស្អីនោះទេ។ ខ បានប្រើឧបាយកលឆបោកទៅកាន់ ក ថាការផ្តល់ជូននេះគឺមានលក្ខខណ្ឌដែលតម្រូវធ្វើលិខិតស្នាមអស់ប្រហែលជា ៥០០ ដុល្លារ ដើម្បីជាភស្តុតាងសម្រាប់ម្ចាស់ជំនួយពិនិត្យ។ ឮដូចនេះ ក ក៏ជឿជាក់ហើយក៏ប្រគល់ប្រាក់គ្រប់ចំនួនតាមការទាមទាររបស់ ខ ដែលខ្លួនបានសន្សំពីចំណូលរបស់កូនស្រី។ បន្ទាប់ពីបានប្រាក់ ខ ក៏គេចខ្លួនបាត់ទៅ។

**ដំណោះស្រាយ** ៖ ខ បានអះអាងដោយប្រើឋានៈក្លែងថាខ្លួនគឺជាប្រធានអង្គការមួយ ហើយបានធ្វើការឆបោកស្ត្រីម្នាក់ឈ្មោះ ក ដែលជាជនពិការមិនអាចប្រកបកិច្ចការចិញ្ចឹមជីវិតខ្លួនឯងបាន។ ភាពពិការនេះត្រូវបានស្តែងចេញមកក្រៅដោយធ្វើឲ្យជនល្មើសអាចសន្និដ្ឋានបានអំពីពិការភាពនោះ ហេតុដូច្នេះបើយោងតាមមាត្រា ៣៧៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩ បុគ្គល ខ ប្រព្រឹត្តអំពើឆបោកដោយមានស្ថានទម្ងន់ទោសចំពោះបុគ្គលទន់ខ្សោយពិសេស ដោយសារពិការភាពនៃជនរងគ្រោះ។ សរុបមកអំពើរបស់ ខ ត្រូវជាប់ពីបទល្មើសឆបោកដែលមានស្ថានទម្ងន់ទោសដែលទាក់ទងទៅនឹងជនរងគ្រោះ។

ករណីពិការភាពមិនមែនជាមូលហេតុក្នុងការថមថយនូវសមត្ថភាព ឬលទ្ធភាពរូបកាយនៅក្នុងការស្វែងរកចំណូលដើម្បីចិញ្ចឹមជីវិត ៖ ប្រសិនបើបុគ្គលណាម្នាក់បានបាត់បង់នូវ អវៈយវៈណាមួយ ប៉ុន្តែមិនមែនជាចំណុចសំខាន់ដែលធ្វើឲ្យបាត់បង់នូវសមត្ថភាពនោះទេ គឺពុំត្រូវបានចាត់ថាជាបុគ្គលទន់ខ្សោយពិសេសនោះទេ។

**ឧទាហរណ៍** ៖ ដាច់ស្លឹកត្រចៀកជាអាទិ៍។

**ស្ថានទម្ងន់ទោសផ្សេងៗ**[3]

ដោយយោងទៅតាមមាត្រា ៣៨០ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ បានបញ្ញត្តិថាអំពើឆបោកត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារពី ២ (ពីរ) ទៅ ៥ (ប្រាំ) ឆ្នាំ កាលបើបទល្មើសនេះបានប្រព្រឹត្ត ៖

- ដោយអ្នករាជការសាធារណៈនៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន។
- ដោយបុគ្គលដែលតែងតាំងខ្លួនជាអ្នករាជការសាធារណៈ។
- ដោយបុគ្គលដែលធ្វើការអំពាវនាវដល់សាធារណៈជន ដើម្បីបោះពុម្ពចេញឱ្យប្រើប្រាស់នូវមូលបត្រ។
- ដោយបុគ្គលដែលធ្វើការអំពាវនាវដល់សាធារណៈជន ដើម្បីអង្គាសមូលនិធិសម្រាប់ជាជំនួយមនុស្សធម៌ ឬសង្គមកិច្ច។
- ជាក្រុមមានការចាត់តាំង។

ដើម្បីឱ្យកាន់តែច្បាស់ យើងខ្ញុំសូមបកស្រាយនូវគោលគំនិតនៃចំណុចនីមួយៗ ដែលទាក់ទងនឹងស្ថានទម្ងន់ផ្សេងៗទៀតចំពោះបទល្មើសឆបោក ៖

➢ កាលបើបទល្មើសប្រព្រឹត្តដោយអ្នករាជការសាធារណៈ នៅក្នុងក្របខណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ៖ សំដៅដល់អ្នករាជាសាធារណៈណា

[3] មាត្រា ៣៨០ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

មួយដែលបានប្រព្រឹត្តបទល្មើសឆបោកទៅលើជនដទៃទៀតត្រូវតែមានស្ថានទម្ងន់ទោស ទោះបីជាកំពុងស្ថិតនៅក្នុងក្របខណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួនក៏ដោយ។

**ឧទាហរណ៍** ៖ លោក ក គឺជាមន្ត្រីដែលបម្រើការងារនៅក្នុងក្រសួងមួយ។ ថ្ងៃមួយក្រសួងដែលលោកកំពុងបម្រើការងារបានប្រកាសជ្រើសរើសមន្ត្រីក្រមការជាច្រើននាក់ ដើម្បីប្រឡងចូលបម្រើការងារ។ បន្ទាប់ពីបានដំណឹងនេះ ក ក៏មានឧបាយកលមួយដោយបានទៅបញ្ចុះបញ្ចូលអ្នកភូមិរបស់គាត់ថា បើបងប្អូនណាចង់ឲ្យកូនរបស់ខ្លួនទៅបម្រើការងារនៅក្នុងក្រសួងដែលខ្លួនធ្វើការ គឺគ្រាន់តែប្រគល់ប្រាក់ចំនួន ៥០០០ ដុល្លារសម្រាប់រត់ការ ហើយចូលបម្រើការងារដោយមិនចាំបាច់ប្រឡង។ អ្នកភូមិរបស់លោក ក ដោយសារតែចង់ឲ្យកូនបម្រើការងារនៅក្នុងក្រសួងនោះ និងជឿទុកចិត្ត ក ដែលជាអ្នកភូមិជាមួយគ្នាទៀតនោះ ក៏បានប្រគល់ប្រាក់ទៅឱ្យ ក តាមការទាមទារ។ បន្ទាប់ពីបានប្រាប់នោះមក ក បានយកទៅចាយវាយតាមចំណង់របស់ខ្លួនទៅវិញ។

➢ កាលបើបទល្មើសប្រព្រឹត្តដោយបុគ្គលដែលតាំងខ្លួនជាអ្នករាជការសាធារណៈ៖ សំដៅដល់បុគ្គលណាម្នាក់ដែលបានប្រើប្រាស់ឋានៈក្លែងថាខ្លួនជាអ្នករាជការសាធារណៈ នៅក្នុងការប្រព្រឹត្តបទល្មើសឆបោក។

**ឧទាហរណ៍** ៖ លោក ស អះអាងថាខ្លួនជាមន្ត្រីរបស់ក្រសួងរៀបចំដែនដី ប៉ុន្តែខ្លួនមិនមែនជាមន្ត្រីនោះទេ។ លោក ស បានចុះទៅតាមជនបទដាច់ស្រយាលហើយបានឆបោកប្រជាពលរដ្ឋថាខ្លួនជាមន្ត្រីដែលក្រសួងបានចាត់តាំងឱ្យមកវាស់វែងដីធ្វើប្លង់រឹងជូនប្រជាពលរដ្ឋក្នុងតម្លៃសមរម្យត្រឹមតែ ៣០ ដុល្លារ ដោយសន្យាថានឹងប្រគល់ប្លង់ជូនក្នុងពេលមួយសប្តាហ៍។ ប្រជាពលរដ្ឋទាំងនោះក៏យល់ព្រមតាមសំណើរបស់លោក ស និងប្រគល់ប្រាក់តាមការទាមទារ ។

➢ កាលបើបទល្មើសប្រព្រឹត្តដោយបុគ្គលដែលធ្វើការអំពាវនាវដល់សាធារណៈជនដើម្បីបោះពុម្ពចេញឱ្យប្រើនូវមូលបត្រ ៖ មូលបត្រនៅក្នុងចំណុចនេះ សំដៅដល់ប័ណ្ណដែលតំណាងឲ្យសិទ្ធិលើកម្មសិទ្ធិរបស់ម្ចាស់ប័ណ្ណនោះទៅលើក្រុមហ៊ុន ដូច្នេះបានសេចក្តីថាជនល្មើសបានប្រើកលល្បិចដោយធ្វើការអំពាវនាវទៅសាធារណៈជនអំពីការលក់នូវប័ណ្ណកម្មសិទ្ធិក្លែងក្លាយណាមួយ ដែលមានចំពោះក្រុមហ៊ុន។

**ឧទាហរណ៍** ៖ លោក ខ បានអះអាងថាខ្លួនជាម្ចាស់ក្រុមហ៊ុនមួយដែលកំពុងប្រកាសលក់ភាគហ៊ុន ដែលក្នុងនោះមួយហ៊ុនមានតម្លៃ ២០០០ ដុល្លារ ទៅឲ្យអ្នកណាដែលចង់បាន។ បន្ទាប់ពីបានអះអាងដូច្នេះ មានពលរដ្ឋជាច្រើនបានចាប់អារម្មណ៍នឹងគម្រោងនេះ ហើយបានទិញភាគហ៊ុនពី ខ។ ប៉ុន្តែបន្ទាប់ពីបានបោះពុម្ពមូលបត្រលក់ភាគហ៊ុនបានច្រើនហើយលោក ខ បានរត់គេចខ្លួនបាត់ ដោយសារតែភាគហ៊ុនដែលលោក ខ បានលក់នោះគឺមានតែឈ្មោះ តែគ្មានក្រុមហ៊ុនពិតប្រាកដទេ។

➢ កាលបើបទល្មើសបានប្រព្រឹត្តដោយបុគ្គលដែលធ្វើការអំពាវនាវដល់សាធារណៈជនដើម្បីអង្គាសមូលនិធិសម្រាប់ជាជំនួយមនុស្សធម៌ ឬសង្គមកិច្ច ៖ សំដៅដល់ជន

ល្មើសបានធ្វើការឃោសនាខ្យល់ក្នុងការស្វែងរកប្រាក់ចូលក្នុងហោប៉ៅរបស់ខ្លួន ក្រោមរូបភាពរៃអង្គាសមូលនិធិដើម្បីជាជំនួយមនុស្សធម៌ ឬសង្គមកិច្ចណាមួយ។

**ឧទាហរណ៍** ៖ បុគ្គល គ បានបង្កើតប័ណ្ណសប្បុរសធម៌ក្លែងក្លាយមួយ ហើយបានដើររៃអង្គាសប្រាក់ពីប្រជាពលរដ្ឋដោយបានប្រើឧបាយកលថាយកទៅជួយជនពិការ និងកុមារកំព្រា ព្រោះតែមានប័ណ្ណបញ្ជាក់ក្លែងក្លាយនេះ ធ្វើឲ្យប្រជាពលរដ្ឋមួយចំនួនបានបរិច្ចាគប្រាក់ទៅឱ្យ គ ដោយគិតក្នុងចិត្តថានឹងបានដល់ក្មេងកំព្រា និងជនពិការទាំងនោះ។ ប៉ុន្តែបន្ទាប់ពីទទួលបានប្រាក់ដែលបានអង្គាសទាំងនោះ គ បែរជាយកទៅចាយវាយផ្ទាល់ខ្លួនទៅវិញ។

- កាលបើបទល្មើសប្រព្រឹត្តដោយបុគ្គលដែលក្រុមមានការចាត់តាំង ៖ បើយោងតាមមាត្រា ៧៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ បានឱ្យនិយមន័យចំពោះក្រុមមានការចាត់តាំងនេះថា ជាការប្រមូលផ្តុំដែលបង្កើតឡើង ឬជាសន្និដ្ឋិភាព (ការព្រមព្រាងគ្នាដោយរបៀបណាក៏ដោយ) ដែលបានធ្វើឡើង ដើម្បីត្រៀមរៀបចំ ឬការប្រព្រឹត្តបទល្មើសមួយ ឬច្រើន។

**ឧទាហរណ៍** ៖ លោក ច ឆ ជ បានជុំគ្នាដើម្បីត្រៀមរៀបចំប្រព្រឹត្តនូវបទល្មើសឆបោកមួយឡើងដោយបានបោះបង្គោលលើដីសាធារណៈរបស់រដ្ឋមួយកន្លែង ដោយអះអាងថាជាដីរបស់ ច និងមាន ឆ ជ ជាសាក្សី ។ មួយរយៈខ្លីមកមានបុគ្គលម្នាក់ឈ្មោះ ឈ ដែលរស់នៅតំបន់ផ្សេងបានចាប់អារម្មណ៍នឹងដីនេះក៏បានទិញយកហើយបានប្រគល់ប្រាក់ទៅឲ្យ ច បន្ទាប់ពីបានប្រាក់ ច ឆ និង ជ ក៏បានគេចខ្លួនបាត់ទៅ។

### **១.១.២ ទោសបន្ថែម**

ជាគោលការណ៍ទោសបន្ថែមអាចប្រកាសទៅបាន លុះត្រាតែទោសនោះត្រូវបានចែងដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុដែលត្រូវចោទប្រកាន់។ ម្យ៉ាងវិញទៀត ទោសបន្ថែមអាចប្រកាសក៏បាន មិនប្រកាសក៏បាន។ ទោសបន្ថែមត្រូវប្រកាសជាកាតព្វកិច្ច ប្រសិនបើច្បាប់ចែងយ៉ាងជាក់លាក់[4]។

ដោយឡែកនៅក្នុងបទល្មើសឆបោកបានចែងកំណត់យ៉ាងជាក់លាក់ ដូចដែលបានបញ្ញត្តនៅក្នុងមាត្រា ៣៨២ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ដូច្នេះបទល្មើសឆបោកត្រូវមានទោសបន្ថែម ពោលគឺត្រូវបន្ថែមទៅលើមូលទោស។

## **១.២ ធាតុផ្សំសត្យានុម័ត**

ធាតុសត្យានុម័ត ឬហៅថា ធាតុសម្ភារៈ សំដៅលើអំពើដែលជនល្មើសបានប្រព្រឹត្តបទល្មើសស្តែងចេញមកខាងក្រៅតាមរយៈអំពើបង្កគ្រោះថ្នាក់ដល់សង្គម បច្ច័យគ្រោះថ្នាក់ដល់សង្គម (ការអន្តរាយ) ដោយមានទំនាក់ទំនងហេតុផលរវាងអំពើ និងបច្ច័យដែលកើតមានដោយសារតែអំពើនោះ។ អំពើបង្កគ្រោះថ្នាក់ដល់សង្គម គឺជាសកម្មភាពជាក់ស្តែង ឬកាយវិការជាក់ស្តែងរបស់មនុស្ស ដែលបានស្តែងចេញ

---

[4] មាត្រា ៥៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

មកបង្កឱ្យមានការអន្តរាយ ឬគម្រាមបង្កឱ្យអន្តរាយដល់ទំនាក់ទំនងសង្គម ដែលច្បាប់ព្រហ្មទណ្ឌបានការពារ។ អំពើនោះ គឺជាកាយវិការសម្ដែងចេញមកខាងក្រៅដែលអាចមើលឃើញរបស់មនុស្សក្រោមរូបភាពជាក់ស្ដែង ដើម្បីសម្រេចនូវគោលបំណងដែលមានគោលដៅនឹងសេចក្ដីប៉ងប្រាថ្នា ឬសង្ឃឹមចង់បាន។

ដើម្បីឱ្យការសិក្សាចំណុចនេះកាន់តែស៊ីជម្រៅ យើងខ្ញុំសូមលើកយកចំណុចមួយចំនួនមកសិក្សាដូចខាងក្រោមនេះ ៖

### ១.២.១ មូលនិធិ តម្លៃ និងទ្រព្យសម្បត្តិ

នៅក្នុងចំណុចនេះ យើងត្រូវយល់ឱ្យច្បាស់នូវអត្ថន័យនៃពាក្យ ៖

-មូលនិធិ ៖ សំដៅទៅលើប្រាក់កាសដែលមានតម្លៃ ហើយអាចចាយវាយបាន។
ឧទាហរណ៍ ៖ លុយ...។

-តម្លៃ ៖ សំដៅលើវត្ថុដែលមានតម្លៃ បូករួមទាំងឯកសារដែលមានតម្លៃផ្សេងៗ។ ឧទាហរណ៍ ៖ មាស ពេជ្រ ប្លង់ដី...។

-ទ្រព្យសម្បត្តិ ៖ សំដៅដល់របស់ ឬអ្វីៗដែលជាកម្មសិទ្ធិ។ ឧទាហរណ៍ ៖ ដីធ្លី ម៉ូតូ រថយន្ត ...។[5]

### ១.២.២ ការប្រើឈ្មោះក្លែង

ការប្រើឈ្មោះក្លែង គឺជាធាតុផ្សំសត្យានុម័តមួយដែលជនល្មើស បានប្រើប្រាស់ជាមធ្យោបាយមួយនៅក្នុងការឆបោកទៅកាន់ជនរងគ្រោះ ដើម្បីទទួលបាននូវ មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិ។ ការប្រើឈ្មោះក្លែងនៅក្នុងបទល្មើសឆបោកត្រូវបានស្ដែងចេញតាមរយៈការប្រើនូវឈ្មោះក្លែងក្លាយក្នុងគោលបំណងដើម្បីយកឈ្មោះនេះទៅប្រើប្រាស់ក្នុងការឆបោក ដែលធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍អ្នកដទៃ។

### ១.២.៣ ការអះអាងលើឋានៈក្លែង

នៅក្នុងបទល្មើសឆបោក ការអះអាងលើឋានៈក្លែង សំដៅដល់ការយកឋានៈណាមួយដែលខ្លួនគ្មាន ទៅអះអាងដល់ជនដទៃទៀត ដើម្បីឱ្យជននោះជឿទុកចិត្ត ដែលជាភាពងាយស្រួលនៅក្នុងការឆបោក ហើយធ្វើឱ្យខូចខាតប្រយោជន៍របស់ជននោះ។ ការប្រព្រឹត្តនូវការអះអាងលើឋានៈក្លែងនេះ ត្រូវបានប្រព្រឹត្តឡើងដោយបានគិតទុកជាមុន និងមានផែនការច្បាស់លាស់។

### ១.២.៤ ការរំលោភលើឋានៈពិតប្រាកដ

ធាតុផ្សំសត្យានុម័តមួយនេះ សំដៅដល់ការយកឋានៈ ឬមុខដំណែងរបស់បុគ្គលដទៃមកប្រើប្រាស់ដោយអះអាងថាខ្លួនជាអ្នកមានឋានៈ តំណែង ឬតួនាទីនេះពិតប្រាកដ ដោយរំលោភលើឋានៈពិតប្រាកដ ហើយបានយកទៅប្រើប្រាស់នៅក្នុងបទល្មើសឆបោក ដែលនាំឱ្យខូចខាតប្រយោជន៍របស់អ្នកដទៃ។ យ៉ាងណាមិញ ការប្រព្រឹត្តបទល្មើសឆបោក ដោយរំលោភលើឋានៈក្លែងនេះ គឺតែងតែមាននូវការរៀបចំទុកជាមុន និងមានផែនការច្បាស់លាស់ផងដែរ។

### ១.២.៥ ការប្រើឧបាយកលទុច្ចរិត

ការប្រើប្រាស់ឧបាយកលទុច្ចរិត គឺជាការប្រើប្រាស់គ្រប់មធ្យោបាយទុច្ចរិត ដើម្បីបញ្ឆោះបញ្ចូល

[5] ឯកសារស្ដីពីការប្រៀបធៀបបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្ត របស់លោកមេធាវី សួន វិសាល

ទោះបីតាមរយៈសម្ដីក្ដី ឬឯកសារក្ដី ក្នុងគោលបំណងឱ្យជនណាម្នាក់ជឿជាក់ ហើយទទួលបាននូវអ្វីមួយដែលធ្វើឱ្យខូចខាតប្រយោជន៍របស់ជននោះ។ សកម្មភាពនៅក្នុងការប្រព្រឹត្តបទល្មើសឆបោកដោយប្រើឧបាយកលទុច្ចរិតនេះ ជាទូទៅគឺប្រព្រឹត្តដោយមានគម្រោងទុកជាមុន និងមានបំណងច្បាស់លាស់។

### ១.២.៦ ការប៉ុនប៉ងនៅក្នុងបទល្មើសឆបោក

ជាការពិតណាស់កាលណាបើបទល្មើសមួយត្រូវបានប្រព្រឹត្តឡើងដែលបានកើតចេញពីឆន្ទៈរបស់ជនល្មើសហើយ ប៉ុន្តែត្រូវបានខានទៅវិញដោយសារកាលៈទេសៈដែលក្រៅអំពីឆន្ទៈរបស់ជនល្មើសនោះត្រូវបានចាត់ទុកថាជាការប៉ុនប៉ង។ ការប៉ុនប៉ងត្រូវបានកំណត់ថា ការប៉ុនប៉ងនៅក្នុងបទឧក្រិដ្ឋត្រូវផ្តន្ទាទោសដូចគ្នាទៅនឹងបទឧក្រិដ្ឋដែលបានសម្រេចផងដែរ។ ដោយឡែកចំពោះបទមជ្ឈិមវិញតុលាការអាចផ្តន្ទាទោសបានលុះត្រាតែ បទល្មើសនោះបានចង្អុលបង្ហាញយ៉ាងច្បាស់អំពីការផ្តន្ទាទោសអំពីការប៉ុនប៉ងនោះ។ យ៉ាងណាមិញ បទល្មើសឆបោកគឺជាបទមជ្ឈិម ដូច្នេះទាមទារឱ្យមានការចែងអំពីការផ្តន្ទាទោសដើម្បីឱ្យសមស្របទៅនឹងមាត្រា ២៧ នៃក្រមព្រហ្មទណ្ឌ តួយ៉ាងនៅក្នុងមាត្រា ៣៨១ នៃក្រមព្រហ្មទណ្ឌបានចែងកំណត់អំពីការប៉ុនប៉ងនៅក្នុងបទល្មើសឆបោក ហើយបានបញ្ញត្តថា ការប៉ុនប៉ងនៅក្នុងបទល្មើសឆបោកនេះ ត្រូវផ្តន្ទាទោសដូចគ្នាទៅនឹងបទល្មើសឆបោកដែរ។

### ១.២.៧ បទល្មើសប្រហាក់ប្រហែលនឹងបទល្មើសឆបោក

បទល្មើសមួយចំនួនដែលមានសភាពប្រហាក់ប្រហែលនឹងការឆបោក ហើយដែលបទល្មើសទាំងនោះមានដូចជា ៖

-បទរំលោភលើភាពល្ងង់ខ្លៅ ឬភាពទន់ខ្សោយ[6]

-បទបន្លំ[7]។

**» បទរំលោភលើភាពល្ងង់ខ្លៅ ឬភាពទន់ខ្សោយ**

ដោយយោងទៅតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៩ បានបញ្ញត្តិថា អំពើទាញយកផលប្រយោជន៍ដោយចេតនាដោយរំលោភលើភាពល្ងង់ខ្លៅ ឬភាពទន់ខ្សោយនៃបុគ្គលភាពដែលបណ្ដាលមកពីអាយុ ស្ថានភាពមានគត៌ ជំងឺ ឬពិការភាព ដោយបង្ខំបុគ្គលនោះឱ្យប្រព្រឹត្តអំពើ ឬមិនប្រព្រឹត្តអំពើដែលធ្វើឱ្យខូចខាតប្រយោជន៍យ៉ាងធ្ងន់ធ្ងររបស់បុគ្គលនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២០០.០០០ (ពីរសែន) រៀល។

**ឧទាហរណ៍** ៖ ក្មេងប្រុសម្នាក់ឈ្មោះ ក មានអាយុ ៨ ឆ្នាំ។ ម្ដាយ ក បានឱ្យទូរសព្ទម៉ាក Iphone 11 pro ទៅ ក លេងក្នុងគោលបំណងដើម្បីឱ្យ ក នៅចាំផ្ទះខណៈពេលដែលខ្លួនទៅផ្សារ។ បន្ទាប់ពីម្ដាយ ក បានទៅផ្សារបាត់ មានបុរសម្នាក់ឈ្មោះ ខ បានចូលទៅនិយាយលេងជាមួយ ក ដែលនៅក្នុងដៃរបស់ ក មានកាន់ប្រដាប់ក្មេងលេងមួយចំនួន។ ពេលនោះ ខ បានលួងលោម ក ឱ្យដូរទូរសព្ទជាមួយនឹងប្រដាប់

[6] មាត្រា ៣៨៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

[7] មាត្រា ៣៨៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

ក្មេងលេងរបស់ខ្លួន ដោយខ្វះការពិចារណាអំពីតម្លៃ **ក** បានយល់ព្រមដោះដូរជាមួយនឹង **ខ**។ បន្ទាប់ពីបានសម្រេច **ខ** ក៏បានគេចខ្លួនបាត់ទៅ។

» **ការបន្លំ**

អំពើបន្លំ គឺជាអំពើរបស់បុគ្គលដែលដឹងខ្លួនថាគ្មានលទ្ធភាពដាច់ខាតនឹងបង់ថ្លៃ ឬដែលសម្រេចចិត្តមិនបង់ថ្លៃ ក្រោមរូបភាព ៖

-ឱ្យគេបម្រើម្ហូបអាហារ ឬភេសជ្ជៈនៅក្នុងរង្គសាល ភោជនីយដ្ឋាន ឬនៅក្នុងគ្រឹះស្ថានដទៃទៀត ដែលបើកចំហដល់សាធារណៈជន។

-ឱ្យគេប្រគល់បន្ទប់មួយ នឹងកាន់កាប់បន្ទប់នេះនៅក្នុងសណ្ឋាគារ ឬគ្រឹះស្ថានដទៃទៀត ដែលបើកចំហដល់សាធារណៈជន។

-ឱ្យគេដឹកជញ្ជូនតាមត្រីចក្រយាន តាមរថយន្តឈ្នួល ឬតាមមធ្យោបាយដឹកជញ្ជូនផ្សេងទៀត។

**ឧទាហរណ៍ ៖**

១. លោក **អ** បានចូលទៅញ៉ាំម្ហូបអាហារ និងភេសជ្ជៈមួយចំនួននៅក្នុងភោជនីយដ្ឋានមួយកន្លែង។ ប៉ុន្តែពេលដែលគិតថ្លៃសេវាលើរបស់ទាំងនោះ **អ** បែរជាឆ្លើយថាគ្មានប្រាក់បង់ទៅវិញ។

២. លោក **ឡ** បានទៅជួលផ្ទះសំណាក់មួយកន្លែង លុះដល់ស្អែកឡើងម្ចាស់ផ្ទះបានមកទារលុយថ្លៃជួលបន្ទប់ តែ **ឡ** បានឆ្លើយថាគ្មានលទ្ធភាពបង់ទេ។

៣. លោក **ហ** បានធ្វើដំណើរតាមរថយន្តឈ្នួលពី ភ្នំពេញ ទៅខេត្តប៉ៃលិន។ លុះដល់គោលដៅដែលត្រូវឈប់ **ហ** បានប្រាប់ថាខ្លួនគ្មានលុយសម្រាប់បង់ថ្លៃធ្វើដំណើរទេ។

**-ទោសដែលត្រូវអនុវត្ត**

អំពើបន្លំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល។

**-ការប៉ុនប៉ង**

អំពើប៉ុនប៉ងនៅក្នុងបទបន្លំត្រូវផ្តន្ទាទោសដូចគ្នាទៅនឹងបទបន្លំ ដូចដែលបានបញ្ញត្តិនៅក្នុងមាត្រា ៣៨៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ផងដែរ[8]។

**-ទោសបន្ថែម**

យោងតាមមាត្រា ៣៨៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ទោសបន្ថែមចំពោះបទបន្លំដូចតទៅនេះអាចត្រូវបានប្រកាស ៖

-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬរយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬរយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

-ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលកើតចេញពីបទល្មើស។

[8] មាត្រា ៣៨៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង។

-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែយ៉ាងច្រើន។

-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារពត៌មាន។

-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃយ៉ាងច្រើន។

## ១.៣ ធាតុផ្សំអត្តនោម័ត

ធាតុអត្តនោម័ត គឺផ្នែកខាងក្នុងនៃបទល្មើស ដែលផ្ទុយទៅនឹងធាតុសត្យានុម័តដែលជាផ្នែកខាងក្រៅនៃបទល្មើស។ ធាតុអត្តនោម័ត ជាកិរិយាផ្លូវចិត្តរបស់ជនល្មើសចំពោះអំពើបង្កគ្រោះថ្នាក់ដល់សង្គមដែលគេបានប្រព្រឹត្ត និងចំពោះបច្ច័យដែលកើតឡើងពីអំពើនោះ។ យើងមិនអាចមើលធាតុអត្តនោម័តឃើញនឹងភ្នែកទៅខាងក្នុងរបស់ជនល្មើសនោះទេ ប៉ុន្តែយើងអាចមើលឃើញនូវធាតុអត្តនោម័ត បានតាមរយៈធាតុសត្យានុម័តដែលជនល្មើសបានប្រព្រឹត្ត។ ទោះបីកំហុសដែលបានប្រព្រឹត្តកើតចេញពីចេតនា ឬអចេតនា កាលណាធាតុនីត្យានុកូលបានបញ្ញត្តិជាបទល្មើស ជនល្មើសនឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។

នៅក្នុងមាត្រា ៤ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៩ បានកំណត់ថា ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត។ ប៉ុន្តែ ក្នុងករណីដែលច្បាប់បានចែងទុកមុន បទល្មើសមួយអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ភាពខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ។ ដោយឡែកនៅក្នុងបទល្មើសឆបោកវិញ ជនល្មើសគឺមានចេតនានៅក្នុងការប្រព្រឹត្តនូវបទល្មើសមួយនេះ ដោយបានខិតខំរិះរកគ្រប់មធ្យោបាយដើម្បីប្រើប្រាស់ក្នុងការបោកបញ្ឆោតឱ្យជនរងគ្រោះជឿទុកចិត្តទៅលើការអះអាងរបស់ខ្លួន ហើយព្រមប្រគល់នូវមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយទៅលើជនល្មើស ទាំងដែលជនរងគ្រោះសង្ឃឹមក្នុងចិត្តថា ខ្លួននឹងទទួលបាននូវផលប្រយោជន៍អ្វីមួយពីជនល្មើសដូចគ្នា។ ម្យ៉ាងវិញទៀតជនល្មើសមានឆន្ទៈប្រព្រឹត្តនូវបទល្មើសឆបោកនេះតាំងតែមុនពេលដែលបទល្មើសមួយនេះបានកើតមកម្ល៉េះ ដោយ ៖

-ជនល្មើសមានចេតនាទុច្ចរិតដើម្បីទទួលបាននូវផលប្រយោជន៍អ្វីមួយពីជនរងគ្រោះជារូបវន្តបុគ្គល ឬនីតិបុគ្គល

-ជនល្មើសមានចេតនាប្រើឈ្មោះក្លែង ឬឋានៈក្លែង ឬប្រើឧបាយកលទុច្ចរិតផ្សេងទៀត ដើម្បីឱ្យជនរងគ្រោះស្រម៉ៃជឿជាក់ ហើយប្រគល់ឱ្យនូវ ៖

· មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ និងជនល្មើសចង់ទទួលបាននូវការផ្ដត់ផ្គង់សេវាដោយឥតគិតថ្លៃ

· លិខិតដែលមានតម្លៃជាកាតព្វកិច្ច

· លិខិតដែលមានតម្លៃឱ្យរួចពីកាតព្វកិច្ច។

# ជំពូកទី២ ៖ បទល្មើសរំលោភលើទំនុកចិត្ត

## ២.១ ធាតុផ្សំនីត្យានុកូល

ដោយយោងទៅតាមមាត្រា ៣៩១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩ បានកំណត់ថា អំពើរំលោភលើទំនុកចិត្ត គឺជាអំពើគែបំបាត់ មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ នាំឱ្យខូចប្រយោជន៍អ្នកដទៃ ប្រព្រឹត្តដោយបុគ្គលណាម្នាក់ ដែលគេបានប្រគល់ឱ្យបុគ្គលនោះ ហើយបុគ្គលនោះបានយល់ព្រម ដោយមានភារកិច្ចប្រគល់សងវិញ បង្ហាញ ឬយកមូនិធិ តម្លៃ ឬទ្រព្យសម្បត្តិនោះ ទៅធ្វើការប្រើប្រាស់ជាកំណត់។

បទល្មើសរំលោភលើទំនុកចិត្តនេះត្រូវផ្តន្ទាទោសតាមមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩។ ដោយឡែកចំពោះការផ្តន្ទាទោសនេះវិញគឺដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

ដោយឡែកបើយើងពិនិត្យមើលទៅលើ ច្បាប់ព្រហ្មទណ្ឌអន្តរកាលវិញ ត្រង់មាត្រា ៤៦ បានបញ្ញត្តអំពីបទល្មើសរំលោភលើសេចក្តីទុកចិត្តថា ជនណាដែលគៃបន្លំ ឬបំបាត់ឱ្យខូចប្រយោជន៍ដល់ម្ចាស់កម្មសិទ្ធិ ម្ចាស់ទីកន្លែង ឬ អ្នកកាន់កាប់ទ្រព្យសម្បត្តិ ប្រាក់កាសទំនិញ ឬ គ្រប់ឯកសារដែលមាន ឬដែលចែងពីកាតព្វកិច្ច ឬការដោះបន្ទុកដែលគេប្រគល់មកឱ្យខ្លួនក្នុងលក្ខណៈនៃការជួល ជាការដាក់តម្កល់ទុក ជាអណត្តិ ជាការឱ្យខ្ចីប្រើ ឬដើម្បីជាការងារមានបៀវត្ស ឬ គ្មានបៀវត្ស ដែលត្រូវប្រគល់ឱ្យគេវិញ ឬធ្វើជាតំណាង ឬសម្រាប់ប្រើប្រាស់ ឬជាមុខការ មានកំណត់ ។ ហើយចំពោះការផ្តន្ទាទោសវិញគឺ មាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល បានកំណត់ការផ្តន្ទាទោសចំពោះការរំលោភលើសេចក្តីទុកចិត្តនេះ ដោយដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ។

ប៉ុន្តែបើយើងក្រឡេកទៅមើលច្បាប់ព្រហ្មទណ្ឌខ្មែរមួយទៀតដែលធ្លាប់បានប្រើប្រាស់នៅក្នុងឆ្នាំ ១៩៦៤ ត្រង់មាត្រា ៥១៥ បានកំណត់ថា បទល្មើសរំលោភលើទំនុកចិត្ត គឺកិរិយាគៃបំបាត់ ឬស៊ីឡិប ជាប្រយោជន៍ខ្លួន ឬជាប្រយោជន៍តតិយជនណាម្នាក់ នូវវត្ថុអ្វីមួយ ដែលគេប្រគល់ភារៈឱ្យខ្លួនរក្សាទុកក្តី ឱ្យដាក់តាំងក្តី ឬឱ្យយកវត្ថុនោះទៅប្រើប្រាស់មានមុខការជាកំណត់ក្តី។

គួរបន្ថែមថា ការរំលោភលើទំនុកចិត្ត ជាបទល្មើសព្រហ្មទណ្ឌប្រឆាំងនឹងការលួចទ្រព្យសម្បត្តិ ដែលកើតឡើងក្នុងពេលដែល ជនជាប់ចោទបានទទួលទ្រព្យសម្បត្តិនោះ ស្របតាមរយៈកិច្ចសន្យាជាមួយម្ចាស់ទ្រព្យសម្បត្តិ ហើយជនជាប់ចោទនោះបានគៃបន្លំយកទ្រព្យសម្បត្តិ ជាអចិន្ត្រៃយ៍ដោយចេតនា។ កិច្ចព្រមព្រៀងរវាងម្ចាស់ទ្រព្យសម្បត្តិ និងជនជាប់ចោទអាចជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់។

### ២.១.១ ស្ថានទម្ងន់ទោស

នៅក្នុងករណីមានស្ថានទម្ងន់នៅក្នុងបទល្មើសរំលោភលើទំនុកចិត្តដែលបានកំណត់នៅក្នុងមាត្រា ៣៩៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ បានបញ្ញត្តិថាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ប្រសិនបើស្ថានទម្ងន់ទោសទាក់ទងនឹងជនល្មើសដូចខាងក្រោម ៖

- ដោយបុគ្គលណាម្នាក់ដែលបានធ្វើការអំពាវនាវដល់សាធារណៈជន ដើម្បីទទួលបានមូលនិធិ ឬតម្លៃសម្រាប់ប្រយោជន៍ផ្ទាល់ ឬជាប្រយោជន៍របស់សហគ្រាសឧស្សាហកម្មពាណិជ្ជកម្ម[9]។

**ឧទាហរណ៍ ៖** ក្រុមហ៊ុនផលិតចំណីអាហាររបស់កម្ពុជាដ៏ល្បីឈ្មោះមួយបានចាត់តាំងលោក **ល** ឱ្យចុះមកបង្រៀនប្រជាពលរដ្ឋនៅតាមសហគមន៍នាតំបន់ជនបទដោយឥតគិតថ្លៃ អំពីរបៀបដាំដុះដំណាំឱ្យទទួលបានផលខ្ពស់ ត្រឹមត្រូវស្របតាមការចង់បានរបស់ក្រុមហ៊ុន និងងាយស្រួលក្រុមហ៊ុនប្រមូលទិញផលដំណាំពីប្រជាកសិករទាំងនោះ។ មានប្រជាពលរដ្ឋជាច្រើនចូលមកសិក្សាវគ្គសិក្សានេះ។ ដោយមើលឃើញមានអ្នកចូលរួមច្រើនយ៉ាងនេះ លោក **ល** ក៏បានទាមទារប្រាក់ថ្លៃបង្រៀនពីប្រជាពលរដ្ឋ ដោយក្នុងម្នាក់ ២ ម៉ឺនរៀល។

- ដោយអាណត្តិគាហករបស់តុលាការ ឬអ្នកជំនួយរបស់តុលាការនៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់ខ្លួន ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន[10]។

**ឧទាហរណ៍** ៖ លោក **ក** ជាជំនួយការមេធាវីម្នាក់ ដែលមានតួនាទីដឹកជញ្ជូនឯកសារនានា។ ថ្ងៃមួយមេធាវី បានជួយធ្វើឯកសារដែលពាក់ព័ន្ធនឹងផ្នែកច្បាប់ដោយឥតគិតថ្លៃជូនស្ត្រីមេម៉ាយម្នាក់ ហើយបានឱ្យ **ក** យកឯកសារនេះទៅជូនស្ត្រីម្នាក់នោះ ប៉ុន្តែបន្ទាប់ពីបានប្រគល់ឯកសារនោះហើយ **ក** បានទាមទារថ្លៃសេវាពីស្ត្រីមេម៉ាយនោះចំនួន ១០០ ដុល្លារទៅវិញ។

- ដោយអ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់ខ្លួន ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន[11]។

**ឧទាហរណ៍** ៖ លោក **ខ** គឺជាមន្ត្រីនគរបាលចរាចរណ៍ម្នាក់ដែលមានតួនាទីផាកពិន័យ និងទុកប្រាក់ដែលបានផាកពិន័យ ពីអ្នកដែលមិនបានគោរពច្បាប់ចរាចរណ៍។ ថ្ងៃមួយ **ខ** ទទួលបានប្រាក់ជាច្រើនពីការផាកពិន័យអ្នកដែលបានបើកបរហួសល្បឿនកំណត់ មិនដាក់ខ្សែក្រវ៉ាត់ មិនពាក់មួកសុវត្ថិភាព និងមិនគោរពភ្លើងសញ្ញាចរាចរណ៍ជាដើម។ ដោយឃើញដូចនេះ **ខ** ក៏មានបំណងគៃបំបាត់នូវប្រាក់មួយចំនួនពីអង្គភាពចូលក្នុងហោប៉ៅរបស់ខ្លួន។

### ២.១.២ ទោសបន្ថែម

ចំពោះបទមជ្ឈិមដែលមានចែងនៅក្នុងផ្នែកនៃការរំលោភលើទំនុកចិត្តនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស[12] ៖

-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

---

[9] កថាខណ្ឌទី១ មាត្រា ៣៩៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

[10] កថាខណ្ឌទី២ មាត្រា ៣៩៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

[11] កថាខណ្ឌទី៣ មាត្រា ៣៩៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

[12] មាត្រា ៣៩៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស។

-ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស។

-ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលកើតចេញពីបទល្មើស។

-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសនោះបានប្រព្រឹត្ត។

-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង។

-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែយ៉ាងច្រើន។

-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។

-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃយ៉ាងច្រើន។

## ២.២ ធាតុផ្សំសត្យានុម័ត

ដើម្បីឱ្យកាន់តែច្បាស់ យើងខ្ញុំសូមលើកយកចំណុចមួយចំនួនមកសិក្សាដូចខាងក្រោម ៖

### ២.២.១ មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិ

នៅក្នុងចំណុចនេះ យើងត្រូវយល់ឱ្យច្បាស់នូវអត្ថន័យនៃពាក្យ ៖

-មូលនិធិ ៖ សំដៅទៅលើប្រាក់កាសដែលមានតម្លៃ ហើយអាចចាយវាយបាន។
ឧទាហរណ៍ ៖ លុយ...។

-តម្លៃ ៖ សំដៅលើវត្ថុដែលមានតម្លៃ បូករួមទាំងឯកសារដែលមានតម្លៃផ្សេងៗ។ ឧទាហរណ៍ ៖ មាស ពេជ្រ ប្លង់ដី...។

-ទ្រព្យសម្បត្តិ ៖ សំដៅដល់របស់ ឬអ្វីៗដែលជាកម្មសិទ្ធិ។ ឧទាហរណ៍ ៖ ដីធ្លី ម៉ូតូ រថយន្ត ...។

### ២.២.២ ការគៃបំបាត់

នៅក្នុងន័យនេះយើងត្រូវយល់ឱ្យបានច្បាស់នូវអត្ថន័យនៃពាក្យ គៃបំបាត់។ យើងសង្កេតឃើញថាពាក្យ គៃបំបាត់នេះ សំដៅដល់ការកេងចំណេញលើអ្នកដទៃនូវទ្រព្យសម្បត្តិ ប្រាក់កាស ទំនិញ ឬឯកសារអ្វីមួយ។ ដោយឡែកចំពោះអ្នកដែលត្រូវបានគេគៃបំបាត់នោះ គឺជាម្ចាស់កម្មសិទ្ធិ ម្ចាស់ទីកន្លែង ឬអ្នកកាន់កាប់។ ពាក្យ ម្ចាស់កម្មសិទ្ធិ សំដៅដល់អ្នកដែលមានសិទ្ធិស្របច្បាប់ ក្នុងការប្រើប្រាស់ អាស្រ័យផល និងចាត់ចែង ដូចជាការលក់ បញ្ចាំ ឬធ្វើអំណោយជាដើម។ ពាក្យ ម្ចាស់ទីកន្លែង សំដៅដល់អ្នកដែលមានសិទ្ធិកាន់កាប់ទៅលើអចលនវត្ថុ ដោយស្របច្បាប់ ហើយវាក៏ប្រហាក់ប្រហែលនឹងពាក្យ អ្នកកាន់កាប់ផងដែរ។ ចំពោះពាក្យ អ្នកកាន់កាប់ វិញគឺសំដៅដល់អ្នកដែលមានសិទ្ធិអាស្រ័យផលទៅលើវត្ថុអ្វីមួយ។[13]

ការគៃបំបាត់ កើតឡើងនៅពេលដែលម្ចាស់ទ្រព្យសម្បត្តិមិនអាចទទួលទ្រព្យសម្បត្តិមកវិញបានជារៀងរហូត។ ជាទូទៅការគៃបន្លំគឺជាការបំផ្លាញទ្រព្យសម្បត្តិនោះដោយលក់ទ្រព្យសម្បត្តិនោះទៅឱ្យភាគីទីបី ឬជាការរក្សាទ្រព្យសម្បត្តិនោះដោយមិនព្រមប្រគល់មកឱ្យម្ចាស់ដើមវិញ។ ជាទូទៅធាតុនេះកើតឡើង នៅ

[13] ការប្រៀបធៀបបទល្មើសឆបោក និងរំលោភលើទំនុកចិត្តរបស់លោកមេធាវី **សួន វិសាល**

ពេលដែលជនជាប់ចោទថ្លោះធ្លោយ មិនបានធ្វើតាមការសន្យាទាក់ទងនឹងទ្រព្យ។ ដែលសេចក្តីនេះថា " ជនណាដែលគៃបន្លំ ឬបំបាត់(ទ្រព្យ) ធ្វើឱ្យខូចប្រយោជន៍ដល់ម្ចាស់កម្មសិទ្ធិ ម្ចាស់ទីកន្លែង ឬអ្នកកាន់កាប់ទ្រព្យ។ ប្រការទាក់ទងនឹងការថ្លោះធ្លោយ គោរពមិនបានតាមការសន្យាក្នុងធាតុទីពីរ ប្រសិនបើជនជាប់ចោទបានសន្យាសងទ្រព្យវិញ នោះគេត្រូវតែខំប្រឹងសងវាវិញ។ បើសិនជាគេបានសន្យាថា ស្នើប្រគល់ឱ្យវិញ នោះគេត្រូវតែខំប្រឹងស្នើប្រគល់វាឱ្យវិញ។ ប្រសិនបើគេបានសន្យាថា នឹងប្រើប្រាស់វាសម្រាប់គោលដៅកំណត់ណាមួយនោះ គេត្រូវតែខំប្រឹងប្រើប្រាស់វាឱ្យត្រូវតាមគោលដៅនោះ។

ការគៃបំបាត់ អាចកើតឡើងតាមវិធីជាច្រើន ប៉ុន្តែរូបភាពទូទៅបំផុតអាចជាការបំផ្លាញទ្រព្យ ការលក់ទៅឱ្យជនទីបី ការរក្សាវាទុក និងបដិសេធមិនព្រមប្រគល់វាឱ្យវិញ ឬមួយប្រើតាមគោលដៅផ្សេងៗទៀត ដែលខុសពីគោលដៅគ្រោងទុកដូចដែលបានព្រមព្រៀងគ្នា។ ជាឧទាហរណ៍ ការគៃបន្លំទ្រព្យអាចកើតឡើង នៅពេលដែលនរណាម្នាក់បានខ្ចីម៉ូតូពីមិត្តភក្តិ រួចលក់ម៉ូតូនោះទៅឱ្យបុគ្គលទីបី។ ដូចគ្នានេះវាអាចកើតឡើង ក្នុងស្ថានភាពដែលនិយោជិតម្នាក់បានទទួលប្រាក់ សម្រាប់យកទៅទិញគ្រឿងប្រើប្រាស់សម្រាប់ការិយាល័យ តែគេបែរជាយកប្រាក់នោះទៅចាក់ល្បែងភ្នាល់បាល់ទាត់ទៅវិញ។ ក្នុងករណីទីពីរនេះសកម្មភាពជនជាប់ចោទបានទប់ស្កាត់ពួកគេ មិនឱ្យធ្វើការតាមសន្យាបានឡើយ។

ធាតុផ្សំនេះ ក៏តម្រូវឱ្យមានការខូចខាតដល់ម្ចាស់ទ្រព្យសម្បត្តិផងដែរ។ ការដែលជនជាប់ចោទបានថ្លោះធ្លោយ មិនបានបំពេញតាមកិច្ចសន្យា វាមិនគ្រប់គ្រាន់ទេ ។ ផ្ទុយទៅវិញការថ្លោះធ្លោយត្រូវតែកើតចេញពីការគៃបំបាត់ ឬការចាត់ចែងលើទ្រព្យសម្បត្តិ ផ្ទុយពីផលប្រយោជន៍របស់ម្ចាស់ទ្រព្យនោះ។ ម្យ៉ាងទៀត ការថ្លោះធ្លោយត្រូវតែមានលក្ខណៈថា ម្ចាស់របស់មិនអាចទទួលទ្រព្យបានមកវិញឡើយ។ ជាឧទាហរណ៍ បើសិនជាបុរសម្នាក់បានជួលរថយន្តមួយ សម្រាប់រយៈពេលមួយសប្តាហ៍ ហើយបានសងវិញយឺតជាងការសន្យាមួយថ្ងៃ នោះគាត់មិនបានគៃបំបាត់យករថយន្តនោះទេ។ ជាការពិតថា គាត់មិនអាចបំពេញតាមលក្ខខណ្ឌកំណត់ដ៏ជាក់លាក់នៃការសន្យាបានមែន ប៉ុន្តែសកម្មភាពរបស់គាត់ មិនធ្វើឱ្យខូចប្រយោជន៍ម្ចាស់ទ្រព្យ ដោយសាររថយន្តនោះទេ។ បុរសរូបនោះ អាចនឹងត្រូវបង់ថ្លៃជួលរថយន្ត មួយថ្ងៃថែមទៀត។ ដោយយោងតាមអត្ថន័យមាត្រា ៣៩១ នៃក្រមព្រហ្មទណ្ឌ បញ្ជាក់ថាសកម្មភាពរបស់គាត់មិនបាន " គៃបំបាត់ឱ្យខូចប្រយោជន៍ ដល់ម្ចាស់រថយន្តនោះឡើយ។ ឧទាហរណ៍ ចំពោះបុរសម្នាក់ទៀតដែលជួលត្រាក់ទ័រសម្រាប់ពេលមួយសប្តាហ៍ ដើម្បីដឹកដីនៅក្នុងភូមិរបស់គាត់ ហើយបានលក់ត្រាក់ទ័រនោះ ទៅឱ្យភាគីទីបី ពិតជាបានគៃបំបាត់ត្រាក់ទ័រនោះមែន ព្រោះម្ចាស់ទ្រព្យ មិនអាចទទួលបានត្រាក់ទ័រនោះ ពីជនជាប់ចោទមកវិញឡើយ។

សរុបមកយើងឃើញថា ការគៃបំបាត់គឺជាការកេងចំណេញ នូវមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិពីជនណាម្នាក់ ហើយតាមរយៈការកេងចំណេញនេះ ធ្វើឱ្យម្ចាស់កម្មសិទ្ធិខូចខាតផលប្រយោជន៍របស់ខ្លួន។

### ២.២.៣ ការប្រគល់ឱ្យមូលនិធិ តម្លៃ និងទ្រព្យសម្បត្តិ

នៅក្នុងចំណុចនេះ ជនល្មើសបានទទួលពីម្ចាស់កម្មសិទ្ធិនូវមូលនិធិ នូវតម្លៃ ឬទ្រព្យ ដោយស្របច្បាប់និងការទុកចិត្តតាមរយៈ

-ការជួល

-ការតម្កល់ទុក

-អាណត្តិ ឬ

-ការឱ្យខ្ចីប្រើ។[14]

ក្នុងការអនុវត្តជាក់ស្តែង ការប្រគល់ទ្រព្យឱ្យអ្នកដទៃ ទំនងជានឹងនិយាយដល់ទម្រង់ណាមួយនៃកិច្ចសន្យាទាំងប្រាំមួយបែប តាមរយៈការកាត់យល់ ឬមួយដាក់ជាក់លាក់។ ក្នុងករណីភាគច្រើន បញ្ហាសំខាន់គឺត្រង់ថា តើគេបានប្រគល់ទ្រព្យឱ្យទៅជនជាប់ចោទឬអត់? មិនមែនប្រភេទកិច្ចសន្យាដែលគេបានបង្កើតឡើង រវាងជនជាប់ចោទ និងម្ចាស់ទ្រព្យឡើយ។ ហេតុដូច្នេះហើយ ការនិយាយអំពីធាតុផ្សំនៃបទល្មើសនេះ ក្នុងករណីភាគច្រើនគេអាចនឹងនិយាយឡើងវិញថា៖"ទ្រព្យត្រូវតែបានគេទុកចិត្តប្រគល់ឱ្យជនជាប់ចោទទទួលខុសត្រូវ"។

ទ្រព្យសម្បត្តិត្រូវបានគេទុកចិត្តប្រគល់ឱ្យទៅជនជាប់ចោទទទួលខុសត្រូវ ម្ចាស់ទ្រព្យសម្បត្តិត្រូវតែបានទុកចិត្តប្រគល់ទៅឱ្យជនជាប់ចោទ ទទួលខុសត្រូវដោយស្របច្បាប់។ ឧទាហរណ៍ដូចជា ការឱ្យប្រាក់ខ្ចី ការផ្ញើរប្រាក់ ឬការបញ្ចាំក្នុងកិច្ចសន្យាណាមួយ។ បើជនជាប់ចោទទទួលបានទ្រព្យសម្បត្តិពីម្ចាស់ដោយខុសច្បាប់ ដូចជាការលួច ឬប្លន់ នោះអំពើនេះគេមិនត្រូវបានរាប់ចូល នៅក្នុងបទល្មើសរំលោភលើទំនុកចិត្តទេ។

## ២.២.៤ ការប្រើប្រាស់ជាកំណត់

នៅក្នុងអត្ថន័យនៃការប្រើប្រាស់ជាកំណត់នេះ មានន័យថាអ្នកកាន់កាប់នូវមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិ ដែលម្ចាស់កម្មសិទ្ធិបានប្រគល់ឱ្យនោះ ត្រូវមានកាតព្វកិច្ចសងត្រឡប់ទៅវិញ។ នៅក្នុងចំណុចនេះ ជនល្មើសបានយល់ព្រមតាមលក្ខខណ្ឌរបស់ម្ចាស់ទ្រព្យ ដូចជាការសងមកម្ចាស់ដើមវិញ ឬត្រូវចាត់ចែង ឬប្រើប្រាស់តាមការកំណត់របស់ម្ចាស់ទ្រព្យ មុននឹងទ្រព្យសម្បត្តិនោះប្រគល់មកឱ្យខ្លួនវិញ។ ក្នុងន័យនេះ ជនល្មើសមានកាតព្វកិច្ចសង ចាត់ចែង ប្រើប្រាស់តាមបំណងរបស់ម្ចាស់កម្មសិទ្ធិ។

បើម្ចាស់ទ្រព្យលក់ទ្រព្យសម្បត្តិ ឬឲ្យវាទៅជនជាប់ចោទ នោះការរំលោភលើទំនុកចិត្តមិនអាចកើតមានឡើងបានទេ។ វាអាចកើតឡើងតែក្នុងករណីដែលគេទុកចិត្តប្រគល់ទ្រព្យសម្បត្តិនោះទៅឲ្យជនជាប់ចោទ ហើយជនជាប់ចោទបានសន្យាថានឹងប្រើប្រាស់ទ្រព្យសម្បត្តិនោះក្នុងគោលបំណងជាក់លាក់ណាមួយ។ ជនល្មើស បានយល់ព្រមប្រគល់សងវិញ តាមលក្ខខណ្ឌរបស់ម្ចាស់ទ្រព្យ ដូចជាការសងមកម្ចាស់ដើមវិញ ឬត្រូវចាត់ចែង ឬប្រើប្រាស់ទ្រព្យតាមការកំណត់របស់ម្ចាស់ទ្រព្យមុននឹងម្ចាស់ទ្រព្យប្រគល់មកឱ្យខ្លួន។ ក្នុងន័យនេះ ជនល្មើសមានកាតព្វកិច្ចសង ចាត់ចែង ឬប្រើប្រាស់តាមបំណងម្ចាស់ទ្រព្យជាការចាំបាច់។

ធាតុផ្សំនេះបង្កប់នៅក្នុងភាសាថា "ដោយបានសន្យាថានឹងសងវិញ ឬប្រគល់ឱ្យវិញ ឬប្រើប្រាស់តាមការព្រមព្រៀងគ្នាណាមួយ"។ ច្បាស់ណាស់ថា ធាតុផ្សំមួយនេះគឺវាអាស្រ័យនឹងអត្ថិភាពនៃធាតុទី២ ដែលថាជនជាប់ចោទ ត្រូវតែបានគេទុកចិត្ត ប្រគល់ទ្រព្យឱ្យទទួលខុសត្រូវ មុននឹងគេអាចសន្យាថា " សង

[14] ការប្រៀបធៀបបទល្មើសឆបោក និងរំលោភលើទំនុកចិត្តរបស់លោកមេធាវី **សួន វិសាល**

វិញ ឬប្រគល់ឱ្យវិញ ឬប្រើប្រាស់តាមការព្រមព្រៀងគ្នាណាមួយ "។ ត្រង់នេះពិពណ៌នានូវទង្វើ ដែលជនជាប់ចោទត្រូវតែបានសន្យាថា នឹងធ្វើចំពោះទ្រព្យនោះ។ ទីមួយ ជនជាប់ចោទ អាចសន្យាថានឹងសងទ្រព្យនោះវិញ។ ការណ៍នេះ ពិពណ៌នាពីស្ថានភាពដែលជនជាប់ចោទ បានខ្ចីរបស់អ្វីមួយ ដូចជារថយន្ត ហើយបានសន្យាថានឹងប្រគល់របស់នោះសងទៅម្ចាស់វិញ។ ជនជាប់ចោទកាន់កាប់ទ្រព្យដោយស្របច្បាប់ ព្រោះម្ចាស់ទ្រព្យ បានប្រគល់វាទៅឱ្យរូបគេដោយស្ម័គ្រចិត្ត ប៉ុន្តែគេបានសន្យាចំពោះម្ចាស់របស់នោះថា នឹងប្រគល់សងវិញ ។ ប្រការនេះបានកំហិតសិទ្ធិរបស់គេ លើទ្រព្យនោះ។ ដូច្នេះគេមិនអាចលក់វា ឬប្រគល់វាជាបន្តឱ្យទៅនរណាម្នាក់ទៀតបានទេ គេត្រូវតែប្រគល់ទ្រព្យនោះសងម្ចាស់ដើមវិញ។ ទីពីរ ដែលធាតុផ្សំនេះត្រូវបំពេញគឺ តាមរយៈការសន្យាថានឹងប្រើប្រាស់ទ្រព្យនោះ តាមការព្រមព្រៀងគ្នា។ ជាថ្មីម្តងទៀត ចំណុចសំខាន់នៅទីនេះគឺ ជនជាប់ចោទបានសន្យាចំពោះម្ចាស់របស់ថា ទប់ស្កាត់ខ្លួនឯងមិនឱ្យចាត់ទុកទ្រព្យនោះ ដូចជារបស់ខ្លួនផ្ទាល់ទេ។ ករណីជាគំរូគឺករណីនយោជិតដែលត្រូវបាននិយោជកទុកចិត្តប្រគល់ប្រាក់ឱ្យកាន់ សម្រាប់បំពេញគោលដៅកំណត់មួយ។ ជាឧទាហរណ៍ និយោជិតនោះត្រូវបាននិយោជកប្រគល់ប្រាក់នោះទៅធនាគារ ប៉ុន្តែគាត់កាន់កាប់វាសម្រាប់តែគោលដៅមួយដែលបានកំណត់តែប៉ុណ្ណោះ គឺយកប្រាក់នោះទៅធនាគារ ហើយដាក់ផ្ញើវានៅទីនោះ។ គេបានធ្វើការសន្យាយ៉ាងជាក់លាក់ ឬតាមការកាត់យល់ ហើយប្រការនោះបានកំហិតលទ្ធភាពរបស់គេ មិនឱ្យចាត់ទុកប្រាក់នោះ ថាជារបស់ផ្ទាល់ខ្លួនទេ។ ចំណុចសំខាន់សម្រាប់ផ្នែកទាំងបីនៃធាតុផ្សំនេះគឺ ជនជាប់ចោទបានសន្យាចំពោះម្ចាស់ទ្រព្យ ដែលដាក់កំហិតដល់សិទ្ធិរបស់គេ ក្នុងការចាត់ចែងការលើទ្រព្យនោះ។ ការរំលោភដោយចេតនាលើទ្រព្យនេះ គឺជាការរំលោភលើទំនុកចិត្ត។

### ២.២.៥ ការប៉ុនប៉ងនៅក្នុងបទល្មើសរំលោភលើទំនុកចិត្ត

ដោយយោងតាមមាត្រា ៣៩៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ បានបញ្ញត្តិថា ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងនៅក្នុងផ្នែកនៃការរំលោភលើទំនុកចិត្តនេះ ត្រូវផ្តន្ទាទោសដូចគ្នាទៅនឹងបទមជ្ឈិមដែលបានកំណត់នៅក្នុងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌដែរ។ ពោលគឺ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល។

### ២.២.៦ បទរំលោភលើទំនុកចិត្តពិសេស

បើយើងពិនិត្យមើលទៅលើមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ បានបញ្ញត្តិអំពើបទរំលោភលើទំនុកចិត្តផ្សេងមួយទៀតគឺ បទរំលោភលើទំនុកចិត្តពិសេស ដោយអភិបាល ឬបុគ្គលផ្សេងទៀត។ នៅក្នុងនោះដែលមាត្រានេះបានបង្ហាញសេចក្តីដូចខាងក្រោម ៖

**-នីត្យានុកូលភាពនៃបទល្មើស**

គ្រប់អភិបាល ឬអ្នកត្រួតពិនិត្យរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលមូលនិធិ ឬបុគ្គលដែលត្រូវបានតុលាការជ្រើសតាំងឱ្យធ្វើជំនួសនូវកិច្ចការរបស់អ្នកទាំងនេះ ឬនិយោជិតដែលទទួលអណត្តិពីនីតិបុគ្គល ដែលប្រព្រឹត្តអំពើណាមួយដែលជាការរំលោភលើទំនុកចិត្ត ក្នុងគោល

បំណងទទួលផលប្រយោជន៍ដល់ខ្លួន ឬតតិយជន ឬក្នុងគោលបំណងធ្វើឱ្យខូចខាតដល់នីតិបុគ្គល ហើយបានបណ្តាលឱ្យមានការខូចខាតទ្រព្យសម្បត្តិរបស់នីតិបុគ្គលនោះ។

**ឧទាហរណ៍** ៖ លោក **ឆ** គឺជាបុគ្គលិកផ្នែកលក់ផលិតផលគ្រឿងសម្អាងដ៏ល្បីរបស់ក្រុមហ៊ុនមួយ ដែលទទួលបានការគាំទ្រពីសំណាក់អ្នកប្រើប្រាស់ជាច្រើន និងរកចំណូលបានខ្ពស់ផងដែរ។ មើលឃើញបែបនេះ **ឆ** ក៏មានគំនិតកិបកេងនូវប្រាក់ចំណេញដែលបានមកពីការលក់ផលិតផល ដោយធ្វើបញ្ជីចំណូលក្លែងក្លាយជូនទៅម្ចាស់ក្រុមហ៊ុន។ មួយរយៈក្រោយមក ក្រុមហ៊ុនបានរកឃើញថាបានបាត់ចំណូលជាច្រើន ក៏បានបើកការស៊ើបអង្កេតទើបដឹងថាជាការគែបំបាត់របស់ **ឆ**។

**-នីត្យានុកូលភាពនៃទោស**

បទរំលោភលើទំនុកចិត្តពិសេស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល។

គួរបញ្ជាក់ផងដែរថា បទប្បញ្ញត្តិខាងលើនេះ(នីត្យានុកូលនៃទោសរំលោភលើទំនុកចិត្តពិសេស) ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះករណីដែលអ្នកជម្រះបញ្ជីរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលមូលនិធិ ឬបុគ្គលដែលត្រូវបានតុលាការជ្រើសតាំងឱ្យធ្វើជំនួសនូវកិច្ចការរបស់អ្នកជម្រះបញ្ជី បានប្រព្រឹត្តអំពើដូចដែលបានកំណត់ខាងលើ[15] ហើយបានបណ្តាលឱ្យមានការខូចខាតទ្រព្យសម្បត្តិរបស់នីតិបុគ្គលនោះ។

**-ការប៉ុនប៉ង**

ការប៉ុនប៉ងប្រព្រឹត្តបទល្មើសនៅក្នុងបទរំលោភលើទំនុកចិត្តពិសេស ដោយអភិបាល ឬបុគ្គលផ្សេងទៀត ត្រូវផ្តន្ទាទោសដូចគ្នាផងដែរទៅនឹងបទល្មើសដែលបានសម្រេច[16]។

## ២.២.៧ បទល្មើសប្រហាក់ប្រហែលនឹងបទល្មើសរំលោភលើទំនុកចិត្ត

នៅក្នុងបទល្មើសដែលមានលក្ខណៈប្រហាក់ប្រហែលនឹងបទល្មើសរំលោភលើទំនុកចិត្ត គឺបទបង្វែរវត្ថុរឹបអូស ឬវត្ថុដាក់ធានា[17]។ បទល្មើសបង្វែរវត្ថុរឹបអូស ឬវត្ថុដាក់ធានា គឺជាអំពើរបស់កូនបំណុលដែលគែបំបាត់ ឬបំផ្លាញវត្ថុដែលបានឃាត់ទុក ឬរឹបអូស ដោយអាជ្ញាធរដែលមាននីតិសម្បទា ឬដាក់ដើម្បីជានានូវសិទ្ធិលើបំណុល។

ចំពោះបទល្មើសនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល។

---

[15] ចំណុចទី ១ នីត្យានុកូលនៃបទល្មើសរំលោភលើទំនុកចិត្តពិសេស

[16] មាត្រា ៣៩៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

[17] មាត្រា ៣៩៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

ដោយឡែកចំពោះការប៉ុនប៉ងនៅក្នុងបទល្មើសបង្វេរវត្ថុរឹបអូស ឬវត្ថុដាក់ធានានេះវិញ ត្រូវផ្តន្ទាទោសដូចគ្នាទៅនឹងបទល្មើសខាងលើដែរ[18]។

## ២.៣ ធាតុអត្តនោម័ត

ដើម្បីសិក្សាចំណុចនេះឱ្យបានត្រឹមត្រូវតាមធាតុផ្សំចិត្តសាស្ត្រ និងស៊ីជម្រៅ យើងខ្ញុំសូមលើយកចំណុច ពីរមកធ្វើការសិក្សានោះគឺ ៖ ចេតនាទុច្ចរិតទូទៅ និងចេតនាទុច្ចរិតពិសេស។

### ២.៣.១ ចេតនាទុច្ចរិតទូទៅ

ប្រសិនបើបុគ្គលម្នាក់មិនបានបំពេញកាតព្វកិច្ចរបស់ខ្លួននៅក្នុងការសងត្រឡប់ទៅវិញនូវ មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិដែលម្ចាស់កម្មសិទ្ធិបានប្រគល់ឱ្យនោះ មិនមែនសុទ្ធសឹងតែជាការរំលោភលើទំនុកចិត្តនោះទេ។ ចំណុចនេះមានន័យថា ការខកខាននៅក្នុងការប្រគល់នូវមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិទៅឱ្យម្ចាស់កម្មសិទ្ធិវិញនោះ ក៏ដោយសារតែមានការរាំងស្ទះពីឆន្ទៈខាងក្រៅ ដូច្នេះករណីនេះមិនត្រូវបានចាត់ទុកថាជាបទល្មើសរំលោភលើទំនុកចិត្តទេ។

**ឧទាហរណ៍** ៖ **បុប្ផា** បានខ្ចីទូរសព្ទម៉ាក Iphone X ពីមិត្តភក្តិរបស់នាងឈ្មោះ **គិរី** ហើយនាងបានសន្យាថានឹងសងទូរសព្ទនោះត្រឡប់ទៅវិញនៅសប្តាហ៍ក្រោយ ។ មិនទាន់ដល់ថ្ងៃដែលត្រូវប្រគល់ទូរសព្ទទៅឱ្យ គិរី វិញផង **បុប្ផា** ត្រូវបានចោរឆក់កាបូបរបស់នាងទៅបាត់ ដែលនៅក្នុងនោះមានទូរសព្ទរបស់ **គិរី** ផងដែរ។ ហេតុដូច្នេះ ធ្វើឱ្យ **បុប្ផា** ខកខាននៅក្នុងការប្រគល់ទូរសព្ទដៃទៅកាន់ម្ចាស់កម្មសិទ្ធិវិញ ប៉ុន្តែនៅក្នុងករណីនេះគេមិនបានចាត់ទុកថាវាជាបទល្មើសរំលោភលើទំនុកចិត្តនោះទេ ដោយហេតុថាអង្គហេតុនេះពុំបានស្តែងចេញឱ្យឃើញនូវចេតនាទុច្ចរិតណាមួយដែលនាំឱ្យខូចខាតប្រយោជន៍របស់អ្នកដទៃនោះទេ។

### ២.៣.២ ចេតនាទុច្ចរិតពិសេស

ក្រោយពីបានយល់នូវចំណុចទាំងអស់ខាងលើ ឥឡូវនេះយើងនឹងបន្តទៅដល់ករណីមានគោលបំណងគៃបំបាត់យកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនវិញម្តង។

ជនល្មើសមានគោលបំណងគៃបំបាត់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិដើម្បីយកមកធ្វើជារបស់ខ្លួនដោយគាត់អាចយកវត្ថុនោះទៅធ្វើការចាយវាយតាមសេចក្តីត្រូវការរបស់ខ្លួន។ នេះបញ្ជាក់ឱ្យឃើញថា ជនល្មើសមានគោលបំណងនៅក្នុងការគៃបំបាត់នូវមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិដែលម្ចាស់កម្មសិទ្ធិបានប្រគល់មកឱ្យធ្វើការប្រើប្រាស់ជាកំណត់ ប៉ុន្តែបើយើងធ្វើការវិភាគឱ្យបានច្បាស់យើងឃើញថា ឆន្ទៈនៃការប្រព្រឹត្តនូវបទល្មើសរំលោភលើទំនុកចិត្តនេះ គឺកើតក្រោយសកម្មភាពនៃការប្រគល់ឱ្យនូវមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិពីសំណាក់ម្ចាស់កម្មសិទ្ធិនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏សកម្មភាពបែបនេះត្រូវបានចាត់ទុកថាជាបទរំលោភលើទំនុកចិត្តផងដែរ។

**ឧទាហរណ៍** ៖ **ក** បានផ្ញើប្រាក់តាមមិត្តភក្តិរបស់ខ្លួនឈ្មោះ **ខ** ដែលធ្វើការជាមួយគ្នានៅភ្នំពេញចំនួន ៥០០ដុល្លារ ទៅឱ្យប្រពន្ធរបស់ខ្លួននៅឯស្រុកកំណើតដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។ បន្ទាប់ពីបានទទួលប្រាក់ **ខ** មានបំណងចង់គៃបំបាត់ប្រាក់ ហើយខ្លួនសម្រេចចិត្តមិនបានប្រគល់ប្រាក់ទៅឱ្យប្រពន្ធរបស់ **ក**

[18] មាត្រា ៣៩៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

ទេ ដោយបែរជាយកប្រាក់ទាំងអស់នោះទៅចាយវាយអស់។ នៅក្នុងករណីនេះ ខ ត្រូវចោទប្រកាន់ចំពោះបទល្មើសរំលោភលើទំនុកចិត្ត ស្របតាមមាត្រា ៣៩១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩ ប៉ុន្តែឆន្ទៈនៅក្នុងការប្រព្រឹត្តនូវបទល្មើសនេះ គឺកើតក្រោយការព្រមព្រៀងប្រគល់ប្រាក់របស់ម្ចាស់កម្មសិទ្ធិ។

សរុបមកយើងឃើញថា ធាតុផ្សំអត្តនោម័តនៃបទល្មើសរំលោភលើទំនុកចិត្ត គឺជនល្មើសមានចេតនាគៃបំបាត់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយពីជនរងគ្រោះមកធ្វើជាប្រយោជន៍ផ្ទាល់ខ្លួន ឬជាប្រយោជន៍របស់តតិយជនណាម្នាក់ បន្ទាប់ពីជនល្មើសបានទ្រព្យសម្បត្តិពីជនរងគ្រោះ ឬក្នុងនាមជាជនរងគ្រោះ។

# ជំពូកទី៣ ៖ ការប្រៀបធៀបបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្ត

ក្រោយពីបាន សិក្សានិងតាមរយៈការបកស្រាយទៅលើបទល្មើសទាំងពីររួចមក យើងឃើញថា បទល្មើសទាំងពីរនេះគឺមានចរិតលក្ខណៈ នៃសញ្ញាណគតិយុត្តដូចគ្នាខ្លះ និងខុសគ្នាខ្លះ ដែលឈានឱ្យយើងយកមកធ្វើការប្រៀបធៀបគ្នាបាន។

## ៣.១ ចំណុចដូចគ្នា

ជាក់ស្តែងនៅក្នុងគន្ថីទី ៣ នេះ គឺមានផ្នែកនៃមាត្រាខ្លះដូចគ្នា តួយ៉ាងដូចជានៅក្នុងបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្តជាដើម។ នៅក្នុងចំណុចនេះយើងនឹងសិក្សាអំពីចរិតលក្ខណៈដូចគ្នាមួយចំនួននៃបទល្មើសទាំងពីរខាងក្រោម៖

### ៣.១.១ ធាតុផ្សំនីត្យានុកូល

យើងបានដឹងហើយថា ធាតុផ្សំនីត្យានុកូល គឺជាធាតុមួយដែលត្រូវបានកំណត់នៅក្នុងច្បាប់ជាធរមាន។ នៅក្នុងការកំណត់របស់ច្បាប់នេះ បទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្តមានលក្ខណៈដូចគ្នា ដែលមានដូចជា ការចែងក្នុងគន្ថី ការចែងនៅក្នុងមាតិកា នីត្យានុកូលភាពនៃទោស និងការប៉ុនប៉ង ហើយដើម្បីឱ្យកាន់តែច្បាស់យើងនឹងធ្វើការសិក្សាទៅលើចំណុចទាំងនេះជាបន្តទៀត។

#### ៣.១.១.១ ចែងនៅក្នុងគន្ថី

ជាការពិតណាស់ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបែងចែកជា ៦ គន្ថី ហើយក្នុងនោះផងដែរ គឺមានតែ ៣ គន្ថីប៉ុណ្ណោះ ដែលមានការកំណត់អំពីបទល្មើស។ គន្ថីនោះរួមមាន គន្ថីទី២ និយាយអំពីអំពីបទល្មើសប្រឆាំងនឹងបុគ្គល គន្ថីទី៣ បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ និងគន្ថីទី៤ និយាយអំពីបទល្មើសប្រឆាំងនឹងជាតិ។ ជាក់ស្តែងចំពោះបទល្មើសឆបោក និងបទរំលោភលើទំនុកចិត្តវិញគឺមានចែងនៅក្នុងគន្ថីទី៣ ដែលនិយាយអំពី បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ។ នេះគឺជាកត្តាសិក្សាមួយដែលនាំឱ្យ នីតិករដាក់បទល្មើសទាំងពីរនេះនៅក្នុងគន្ថីតែមួយ ព្រោះបទល្មើសទាំងពីរនេះមានជាប់ទាក់ទងនឹងទ្រព្យសម្បត្តិដូចគ្នា ហើយធ្វើឱ្យប៉ះពាល់ដល់កម្មសិទ្ធិរបស់បុគ្គល រួមមានទ្រព្យសម្បត្តិ ឬ វត្ថុមានតម្លៃផ្សេងៗដូចគ្នាជាដើម។

#### ៣.១.១.២ ចែងក្នុងមាតិកា

ដើម្បីជាគន្លឹះក្នុងការស្វែងយល់ឱ្យកាន់តែងាយស្រួលទៀតនោះ នីតិករបានរៀបរៀងតាក់តែងក្រមនេះឡើងទៅតាមបែបបទ រចនាសម្ព័ន្ធតាមលំដាប់នៃផ្នែកនីមួយៗតាមលំដាប់លំដោយ។ ដែលនៅក្នុងគន្ថីខ្លះមានមាតិកាតិច ឬច្រើន គឺវាអាស្រ័យទៅលើវិសាលភាពនៃគន្ថីនោះ ម្យ៉ាងវិញទៀត ចំពោះបទល្មើសទាំងពីរ គឺមានចែងជាមួយគ្នាដែលជាប់ទាក់ទងនឹងការយកទ្រព្យសម្បត្តិអ្នកដទៃមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនដោយទុច្ចរិត។

#### ៣.១.១.៣ នីត្យានុកូលភាពនៃទោស

ធាតុនីត្យានុកូលនៃទោស គឺសំដៅលើលក្ខខណ្ឌនៃអំពើណាមួយ ហើយដែលច្បាប់បានចែងច្បាស់លាស់ក្នុងផ្នែកនៃមាត្រាណាមួយក្នុងក្រមព្រហ្មទណ្ឌ ដោយកំណត់ថាជាបទល្មើសដែលអាចធ្វើ

ការផ្តន្ទាទោសបានចំពោះអំពើប្រព្រឹត្តនោះ។ មានតែទោសដែលមានចែងនៅក្នុងក្រមជាធរមានប៉ុណ្ណោះទើបអាចប្រកាស និងផ្តន្ទាទោសបាន។ ជាក់ស្តែង គោលលការណ៍នីត្យានុកូលភាពនៃទោស ដែលមានចែងនៅក្នុងក្រមនេះ បានធ្វើការកំណត់យ៉ាងច្បាស់លាស់ អំពីកម្រិតនៃការផ្តន្ទាទោស។

យ៉ាងណាមិញទោសដែលត្រូវបានប្រកាសចំពោះបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្តគឺ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ។ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល។

**៣.១.១.៤ ការប៉ុនប៉ង**

នៅក្នុងច្បាប់ គឺបានកំណត់អំពីការប៉ុនប៉ងរវាងបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្តគឺត្រូវផ្តន្ទាទោសដូចគ្នាចំពោះបទល្មើបានសម្រេចផងដែរ។ ជាគោលការណ៍ ការប៉ុនប៉ង អាចត្រូវផ្តន្ទាទោសបានចំពោះបទល្មើសមជ្ឈិម។

ម្យ៉ាងទៀត លុះត្រាតែច្បាប់បានចែងកំណត់អំពីការប៉ុនប៉ង នៃបទល្មើសជាមុនសិនទើបតុលាការអាចប្រកាស ផ្តន្ទាទោសពីការប៉ុនប៉ងនោះបាន។ ជាក់ស្តែងការប៉ុនប៉ងចំពោះបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្តមានការកំណត់អំពីការប៉ុនប៉ងដូចគ្នា ដោយបទល្មើសឆបោកត្រូវបានចែងកំណត់នៅក្នុងមាត្រា ៣៨១ ចំណែកឯបទល្មើសរំលោភលើទំនុកចិត្តវិញ ការប៉ុនប៉ងគឺមានចែកក្នុងមាត្រា ៣៩៥។

## ៣.១.២ ប្រធាននៃបទល្មើស

ដូចគ្នានេះដែរ ចំពោះអំពើដែលជាបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្ត បានកំណត់ដល់ស្ថានភាពដែលប្រព្រឹត្តឡើងដោយរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបង្កឡើងក្នុងន័យទទួលបាននូវផលប្រយោជន៍ណាមួយដោយទុច្ចរិត អំពើនោះត្រូវបានច្បាប់បញ្ញត្តិថាជាបទល្មើស។ ដូច្នេះ យើងអាចសន្និដ្ឋានបានមិនថានីតិបុគ្គលឯកជន ឬនីតិបុគ្គលសាធារណៈនោះទេ គឺសុទ្ធតែជាប្រធាននៃបទល្មើសទាំងអស់។

**៣.១.២.១ ជនរងគ្រោះ**

វាជាព្យសនកម្មមួយ ដែលសំដៅដល់ការមិនអាចទទួលបានមកវិញនូវទ្រព្យសម្បត្តិ តាមរយៈការព្រមព្រៀងប្រគល់នូវទ្រព្យសម្បត្តិណាមួយដែលមានតម្លៃ ដូចជាការប្រគល់មូនិធិ តម្លៃ ឬការផ្គត់ផ្គង់សេវា និងការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ជាសកម្មភាពដែលធ្វើឱ្យមានការខូចខាត និងបាត់បង់ផលប្រយោជន៍របស់ជនរងគ្រោះ។ យ៉ាងណាមិញ ចំពោះបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្តបានបង្ហាញនូវការខូចខាតដូចគ្នា ហើយដែលការខូចខាតនោះគឺ មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយរបស់ជនរងគ្រោះ។

**៣.១.២.២ ជនល្មើស**

ក្នុងស្ថានភាពនៃសកម្មភាពរបស់ជនល្មើស គឺមានចេតនាទុច្ចរិត ជាការបំភាន់ ឬក្លែងនូវឋានៈ ឬស្ថិតក្នុងមុខងារជាអ្នករាជការសាធារណៈ ជាក្រុមមានការចាត់តាំងណាមួយ ដែលធ្វើការអំពាវនាវដល់សាធារណៈជន ដើម្បីទទួលបាននូវ មូនិធិ តម្លៃ សេវា ឬទ្រព្យសម្បត្តិអ្វីមួយ ជាការគៃបន្លំ ក្នុងបំណងធ្វើឱ្យ

ខូចប្រយោជន៍ដល់ម្ចាស់កម្មសិទ្ធិ ម្ចាស់ទីកន្លែង ឬអ្នកកាន់កាប់។ មែនទែនទៅ ជនល្មើស មានចេតនាធ្វើអំពើមួយនេះ ដោយដឹងថាអ្វីដែលគាត់បានធ្វើជាអំពើខុសដែលនេះវាមិនមែនជាកំហុសដោយចៃដន្យ ឬដោយប្រធានសក្តិនោះឡើយ។

**៣.១.៣ ព្យសនកម្ម**

បើពិនិត្យមើលទៅលើធាតុផ្សំនៃបទល្មើស ព្យសនកម្មនេះកើតឡើង នៅពេលដែលអំពើមួយនាំឱ្យមានការខូចខាត ឬប៉ះពាល់ផលប្រយោជន៍ដល់ម្ចាស់របស់ នូវមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ ដោយម្ចាស់កម្មសិទ្ធិបានបាត់បង់ ឬមិនអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនទៅលើវត្ថុនោះបាន ដោយឧបាយកលទុច្ចរិតណាមួយរបស់ភាគី។

**៣.១.៤ ចំណាត់ថ្នាក់នៃបទល្មើស**

បទល្មើសព្រហ្មទណ្ឌត្រូវបានត្រូវបានបែងចែកជាបីថ្នាក់ដូចបានកំណត់យ៉ាងច្បាស់ក្នុងក្រមព្រហ្មទណ្ឌត្រង់មាត្រា២ វាក្យខណ្ឌទី២ បានចែងថាបទល្មើសត្រូវបានចាត់ថ្នាក់បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុទៅតាមស្ថានទម្ងន់នៃបទល្មើស។

**បទល្មើសជាបទឧក្រិដ្ឋ**[19] ៖

បទល្មើសឧក្រិដ្ឋ នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវទទួលរងនោះ ៖

- ជាទោសដាក់ពន្ធនាគារអស់មួយជីវិត
- ជាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី៥ឆ្នាំ ឬក្រោម ឬស្មើ៣០ឆ្នាំ។ ហើយទោសនេះអាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។

**បទល្មើសជាបទមជ្ឈិម**[20] ៖

បទល្មើសជាបទមជ្ឈិម នៅក្នុងករណីដែលអតិបរមា នៃទោសដាក់ពន្ធនាគារ ដែលត្រូវរងនោះមានរយៈពេលលើសពី៦ថ្ងៃ ដល់ក្រោម ឬស្មើ៥ឆ្នាំ។

**បទល្មើសជាបទលហុ**[21]៖

- អតិបរមា នៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះមានរយៈពេលស្មើ ឬក្រោម៦ថ្ងៃ។ ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យ ជាប្រាក់ផងដែរ។
- បទល្មើសត្រូវផ្តន្ទាទោសត្រឹមតែពិន័យប្រាក់ប៉ុណ្ណោះ ។

ដោយឡែកចំពោះបទល្មើសឆបោក និងបទល្មើសរំលោភលើទនុកចិត្ត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចន្លោះ៦ខែ ទៅ ៣ឆ្នាំ ដូច្នេះបទល្មើសទាំងពីរនេះត្រូវស្ថិតនៅក្នុងចំណាត់ថ្នាក់នៃបទមជ្ឈិមដូចគ្នា ព្រោះអតិបរមានៃទោសពន្ធនាគារមិនលើសពី៥ឆ្នាំទេ។ បើយោងទៅតាមមាត្រា៤៧ នៃក្រមនេះ បាន

[19] មាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

[20] មាត្រា ៤៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

[21] មាត្រា ៤៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

ឱ្យនិយមន័យថា បទល្មើសជាបទមជ្ឈិម នៅករណីដែលអតិបរមា នៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះមានរយៈពេលលើសពី៦ថ្ងៃ ដល់ក្រោមឬស្មើ ៥ឆ្នាំ។

### ៣.១.៥ អាជ្ញាយុកាល

**អាជ្ញាយុកាលនៃបទល្មើស[22]**

អាជ្ញាយុកាលគឺជារយៈពេលមួយដែលច្បាប់កំណត់ នៃការទទួលខុសត្រូវ ឬមិនទទួលខុសត្រូវចំពោះមុខច្បាប់។ ចំពោះអាជ្ញាយុកាលនៃបទល្មើស គឺជារយៈពេលមួយដែលត្រូវរាប់ គឺគិតចាប់ពីពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត ទោះបានសម្រេច ឬមិនបានសម្រេច។ ចំពោះអាជ្ញាយុកាល នៃបទល្មើសទាំងពីរវិញគឺមាន អាជ្ញាយុកាល រយៈពេល៥ឆ្នាំដូចគ្នា ដោយរាប់ចាប់ពីពេលបទល្មើសបានប្រព្រឹត្តចប់។

អាជ្ញាយុកាលនៃបទល្មើសត្រូវបានគេបែងចែកជាបីទៀតគឺ ៖

- អាជ្ញាយុកាល នៃបទល្មើសឧក្រិដ្ឋមានរយៈពេល ១៥ ឆ្នាំ។
- អាជ្ញាយុកាល នៃបទមជ្ឈិមមានរយៈពេល ៥ ឆ្នាំ។
- អាជ្ញាយុកាល នៃបទលហុមានរយៈពេល ១ ឆ្នាំ។

**អាជ្ញាយុកាលនៃទោស[23]**

អាជ្ញាយុកាលនៃទោស គឺជាថេរវេលាមួយដែលត្រូវរាប់ចាប់ពីពេលដែលទោសត្រូវបានប្រកាសដោយចៅក្រម ហើយទោសនោះបានចូលជាស្ថាពរ។ ទោសដែលត្រូវបានប្រកាសនោះផុតរយៈពេលដែលកំណត់ដោយច្បាប់នេះ មិនអាចយកទោសនោះទៅអនុវត្តបានទៀតឡើយ។ ហើយអាជ្ញាយុកាលនៃទោសត្រូវបានបែងចែកជាបីដូចជា៖

- អាជ្ញាយុកាល នៃបទល្មើសឧក្រិដ្ឋមានរយៈពេល ២០ឆ្នាំ។
- អាជ្ញាយុកាល នៃបទមជ្ឈិមមានរយៈពេល ៥ឆ្នាំ។
- អាជ្ញាយុកាល នៃបទលហុមានរយៈពេល ១ឆ្នាំ។

ចំណែកឯបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្តវិញ អាជ្ញាយុកាលនៃទោសគឺមានរយៈពេលល ៥ ឆ្នាំដូចគ្នា ដោយរាប់ចាប់ពីពេលដែលសាលក្រមបានចូលជាស្ថាពរ។

## ៣.២ ចំណុចខុសគ្នា

បន្ទាប់ពីបានឃើញតាមរយៈការបកស្រាយកន្លងមក យើងអាចកំណត់អំពីចំណុចខុសគ្នាមួយចំនួន ហើយដែលចំណុចទាំងនោះ នឹងត្រូវបានលើកយកមកបកស្រាយតាមរយៈធាតុ បី គឺ ៖ ធាតុនីត្យានុកូល ធាតុសត្យានុម័ត និងធាតុអត្តនោម័ត។

### ៣.២.១ ធាតុផ្សំនីត្យានុកូល

នៅក្នុងធាតុនេះ យើងអាចដឹងបានតាមរយៈការចែងជាធរមានចំពោះអំពើណាមួយដែលជាបទល្មើស។ ហេតុដូច្នេះ យើងអាចមើលឃើញនូវលក្ខណៈខុសគ្នារវាងបទល្មើសទាំងពីរដូចខាងក្រោម ៖

[22] មាត្រា ១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[23] មាត្រា ១៤៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

### ៣.២.១.១ នីត្យានុកូលភាពនៃបទល្មើស

**អំពើឆបោក** គឺជាអំពើបន្លំចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយ ដោយប្រើឈ្មោះក្លែងដោយអះអាងទៅលើ ឋានៈក្លែង ដោយរំលោភទៅឋានៈពិតប្រាកដ ឬដោយប្រើឧបាយកលទុច្ចរិត ហើយដូច្នេះបានទទួលពីបុគ្គលនេះ ដែលនាំឱ្យខូចប្រយោជន៍ដល់បុគ្គលនេះ ឬរបស់តតិយជននូវ៖

- ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ។
- ការផ្តត់ផ្គង់សេវា ។
- ការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬជាការឱ្យរួចពីកាតព្វកិច្ច។

បទល្មើសនេះត្រូវបានចែងយ៉ាងច្បាស់នៅក្នុង ៣៧៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩។

**អំពើរំលោភលើទំនុកចិត្ត** គឺជាអំពើគែបំបាត់ មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ នាំឱ្យខូចប្រយោជន៍អ្នកដទៃ ប្រព្រឹត្តដោយបុគ្គលណាម្នាក់ ដែលគេបានប្រគល់ឱ្យបុគ្គលនោះ ហើយបុគ្គលនោះបានយល់ព្រម ដោយមានភារកិច្ចប្រគល់សងវិញ បង្ហាញ ឬយកមូនិធិ តម្លៃ ឬទ្រព្យសម្បត្តិនោះ ទោធ្វើការប្រើប្រាស់ជាកំណត់។

បទល្មើសរំលោភលើទំនុកចិត្តនេះ ត្រូវបានចែងយ៉ាងច្បាស់នៅក្នុងមាត្រា៣៩១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩។

ដូច្នេះឆ្លងតាមរយៈការបកស្រាយនៅក្នុងចំណុចនេះ យើងអាចមើលឃើញថានីត្យានុកូលភាពនៃទោសរបស់បទល្មើសទាំងពីរមានភាពខុសគ្នាយ៉ាងច្បាស់ ទាំងការប្រើប្រាស់ពាក្យពេចន៍ បូករួមទាំងអត្ថន័យនៅក្នុងបទល្មើសផងដែរ។

### ៣.២.១.២ ការចែងក្នុងជំពូក

បើយើងពិនិត្យមើលទៅលើក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៩ ដែលកំពុងប្រើប្រាស់បច្ចុប្បន្ននេះ គឺត្រូវបានបែងចែកជា ៦ គន្ថី ហើយដែលនៅក្នុងគន្ថីទាំងនោះ បានចែកចេញជាមាតិកា ជំពូក ផ្នែក និងមាត្រាផ្សេងៗទៀត។ ដោយឡែកចំពោះបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្តត្រូវបានបែងចែកនៅក្នុងជំពូកដាច់ដោយឡែកពីគ្នា គឺ ៖

**បទល្មើសឆបោក** ត្រូវបានចែងនៅក្នុង ជំពូកទី ២[24] នៃមាតិកាទី ១ គន្ថីទី ៣ ហើយដែលនៅក្នុងជំពូកនេះបានកំណត់អំពីផ្នែកចំនួន ពីរ ទៀតដូចជា ៖

-ផ្នែកទី ១ ការឆបោក : បានកំណត់អំពី និយមន័យនៃការឆបោក (មាត្រា ៣៧៧) ទោសដែលត្រូវអនុវត្ត (មាត្រា ៣៧៨) ស្ថានទម្ងន់ទោសដែលទាក់ទងទៅនឹងជនរងគ្រោះ (មាត្រា ៣៧៩) ស្ថានទម្ងន់ទោសផ្សេងទៀត (មាត្រា ៣៨០) ការប៉ុនប៉ង (មាត្រា ៣៨១) និង ទោសបន្ថែម (មាត្រា ៣៨២)។

-ផ្នែកទី ២ បទល្មើសប្រហាក់ប្រហែលនឹងការឆបោក : បានកំណត់អំពី បទរំលោភលើភាពល្ងង់ខ្លៅ ឬភាពទន់ខ្សោយ (មាត្រា ៣៨៣) បទបន្លំ (មាត្រា ៣៨៤) ការប៉ុនប៉ងនៅក្នុងបទបន្លំ (មាត្រា ៣៨៥) ទោសបន្ថែមនៅក្នុងបទបន្លំ (មាត្រា ៣៨៦)។

---

[24] ការឆបោក និងបទល្មើសប្រហាក់ប្រហែល

ចំណែកឯ បទល្មើសរំលោភលើទំនុកចិត្តវិញ ត្រូវបានចែងនៅក្នុង ជំពូកទី ៣[25] នៃមាតិកាទី ១ គន្ថីទី ៣ ដែលនៅក្នុងជំពូកនេះបានកំណត់អំពីផ្នែកចំនួន ពីរ ទៀតគឺ ៖

-ផ្នែកទី ១ ការរំលោភលើទំនុកចិត្ត : បានកំណត់អំពី និយមន័យនៃការរំលោភលើទំនុកចិត្ត (មាត្រា ៣៩១) ទោសដែលត្រូវអនុវត្ត (មាត្រា ៣៩២) បទរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត (មាត្រា ៣៩៣) ស្ថានទម្ងន់ដែលទាក់ទងទៅនឹងជនល្មើស (មាត្រា ៣៩៤) ការប៉ុនប៉ង (មាត្រា ៣៩៥) និង ទោសបន្ថែម (មាត្រា ៣៩៦)។

-ផ្នែកទី ២ ការបង្វែរវត្ថុរឹបអូស ឬដាក់ធានា : បានកំណត់អំពី បទបង្វែរវត្ថុរឹបអូស ឬវត្ថុដាក់ធានា (មាត្រា ៣៩៧) និងការប៉ុនប៉ង (មាត្រា ៣៩៨)។

**៣.២.១.៣ ស្ថានទម្ងន់ទោស**

ជាការពិតណាស់ស្ថានទម្ងន់ទោស ដែលត្រូវបានអនុវត្តចំពោះបទល្មើសទាំងឡាយណាដែលបានប្រព្រឹត្តដោយ ក្រុមមានការចាត់តាំង ការគិតទុកជាមុន ការកាប់គាស់ទម្លុះទម្លាយ ការផ្លោះរបងចូល ការប្រើប្រាស់អាវុធ និងវត្ថុដែលត្រូវបានចាត់ទុកថាជាអាវុធ និងការពួនស្ទាក់ជាដើម។ ស្ថានទម្ងន់ទោសនេះអាចប្រកាសទៅបានលុះត្រាតែ ស្ថានទម្ងន់នោះបានកំណត់យ៉ាងច្បាស់នៅក្នុងបទល្មើសដែលមានចែងជាធរមាន។ យ៉ាងណាមិញ បទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្ត មានស្ថានទម្ងន់ទោសដូចគ្នាប៉ុន្តែប្រភេទនៃស្ថានទម្ងន់នៃបទល្មើសទាំងពីរមានលក្ខណៈខុសគ្នា ដោយក្នុងនោះ ៖

-បទល្មើសឆបោក ៖ មានស្ថានទម្ងន់ដែលត្រូវបានកំណត់ នៅក្នុងបទល្មើសនេះមានពីរគឺ ស្ថានទម្ងន់ទោសដែលទាក់ទងទៅនឹងជនរងគ្រោះ និងស្ថានទម្ងន់ផ្សេងទៀត។

-ស្ថានទម្ងន់ទោសដែលទាក់ទងទៅនឹងជនរងគ្រោះ

អំពើឆបោក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ កាលបើអំពើនេះបានប្រព្រឹត្តនាំឲ្យខូចប្រយោជន៍ ៖

- បុគ្គលដែលទន់ខ្សោយពិសេស ដោយសារមូលហេតុអាយុនៃបុគ្គលនោះ។
- នារីមានគភ៌ កាលបើមានគភ៌ ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង។
- បុគ្គលដែលទន់ខ្សោយពិសេស ដោយសារមូលហេតុនៃជម្ងឺ ឬពិការភាព កាលបើស្ថានភាពបុគ្គលនោះត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង។

-ស្ថានទម្ងន់ផ្សេងទៀត

ដោយយោងទៅតាមមាត្រា ៣៨០ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ បានបញ្ញត្តិថាអំពើឆបោកត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ទៅ ៥ (ប្រាំ) ឆ្នាំ កាលបើបទល្មើសនេះបានប្រព្រឹត្ត ៖

ក . ដោយអ្នករាជការសាធារណៈនៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ។

ខ . ដោយបុគ្គលដែលតែងតាំងខ្លួនជាអ្នករាជការសាធារណៈ។

[25] ការរំលោភលើទំនុកចិត្ត និងអំពើប្រហែល

**គ** . ដោយបុគ្គលដែលធ្វើការអំពាវនាវដល់សាធារណៈជន ដើម្បីបោះពុម្ពចេញឱ្យប្រើប្រាស់នូវមូលបត្រ។

**ឃ** . ដោយបុគ្គលដែលធ្វើការអំពាវនាវដល់សាធារណៈជន ដើម្បីអង្គាសមូលនិធិសម្រាប់ជាជំនួយមនុស្សធម៌ ឬសង្គមកិច្ច។

**ង** . ជាក្រុមមានការចាត់តាំង។

-ចំពោះបទល្មើសរំលោភលើទំនុកចិត្តវិញ មាន៖

- ដោយបុគ្គលណាម្នាក់ដែលបានធ្វើការអំពាវនាវដល់សាធារណៈជន ដើម្បីទទួលបានមូលនិធិ ឬតម្លៃសម្រាប់ប្រយោជន៍ផ្ទាល់ ឬជាប្រយោជន៍របស់សហគ្រាសឧស្សាហកម្មពាណិជ្ជកម្ម។
- ដោយអណត្តិគាហករបស់តុលាការ ឬអ្នកជំនួយរបស់តុលាការនៅក្នុងក្រមខ័ណ្ឌនៃមុខងាររបស់ខ្លួន ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន។
- ដោយអ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់ខ្លួន ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន។

**៣.២.១.៤ ទោសបន្ថែម**

ដោយយោងទៅតាមមាត្រា ៥៤ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៩ បានបញ្ញត្តថា ទោសបន្ថែមនេះអាចប្រកាសទៅបានលុះត្រាតែទោសនេះត្រូវបានចែងយ៉ាងជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ដែលត្រូវចោទប្រកាន់។ ទោសបន្ថែមអាចប្រកាសក៏បាន មិនប្រកាសក៏បាន។ ទោសបន្ថែមត្រូវប្រកាសជាកាតព្វកិច្ច ប្រសិនបើច្បាប់ចែងយ៉ាងជាក់លាក់។

ដោយឡែកចំពោះបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្ត មានការចែងអំពីទោសបន្ថែមដែលអាចត្រូវបានប្រកាស ប៉ុន្តែចំនួនទោសបន្ថែមនៃបទល្មើសទាំងពីរមានភាពខុសគ្នា គឺ ៖

-បទល្មើសឆបោក មានទោសបន្ថែមចំនួន ១៣[26]

- ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។
- ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់ រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។
- ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើនចំពោះបទមជ្ឈិម។
- ការហាមឃាត់ចំពោះទណ្ឌិតបរទេសចំពោះការចូល ឬស្នាក់នៅក្នុងដែនដីនៃ ព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។
- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស។
- ការរឹបអូស ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស។
- ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលកើតចេញពីបទល្មើស។

[26] មាត្រា ៣៨២ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត។
- ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង។
- ហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។
- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន។
- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារពត៌មាន។
- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន។

-ចំពោះ**បទល្មើសរំលោភលើទំនុកចិត្ត**វិញ មានទោសបន្ថែមចំនួនត្រឹមតែ ១០[27] ប៉ុណ្ណោះ ដែលចំនួននេះតិចជាងចំនួនទោសបន្ថែមនៅក្នុងបទល្មើសឆបោកចំនួន ៣ ដោយក្នុងនោះមាន ៖

- ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។
- ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។
- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស។
- ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស។
- ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលកើតចេញពីបទល្មើស។
- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសនោះបានប្រព្រឹត្ត។
- ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង។
- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែយ៉ាងច្រើន។
- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។
- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃយ៉ាងច្រើន។

### ៣.២.២ ធាតុសត្យានុម័ត

នៅក្នុងធាតុសត្យានុម័ត (ធាតុសម្ភារៈ) សំដៅដល់សកម្មភាពដែលបានស្តែងចេញមកខាងក្រៅ ហើយអាចឱ្យយើងសង្កេតឃើញជាសម្ភារៈខាងក្រៅយ៉ាងច្បាស់។ ដូច្នេះដើម្បីយល់ច្បាស់អំពីភាពខុសគ្នារវាងបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្តនៅក្នុងធាតុផ្សំសត្យានុម័ត យើងនឹងធ្វើការសិក្សានៅចំណុចខាងក្រោម ៖

#### ៣.២.២.១ រូបភាពនៃអំពើ

រូបភាពនៃអំពើ សំដៅដល់សកម្មភាពណាមួយរបស់ជនល្មើសដែលប្រព្រឹត្តទៅកាន់ជនរងគ្រោះ។

[27] មាត្រា ៣៩៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

ការប្រព្រឹត្តបទល្មើសនីមួយៗតែងតែបានបង្ហាញនូវសកម្មភាពមកខាងក្រៅ ហើយសកម្មភាពនោះទៀតសោតត្រូវបានច្បាប់កំណត់ថាជាបទល្មើស។ ដូច្នេះនៅក្នុងចំណុចនេះ យើងនឹងធ្វើការសិក្សាទៅលើចំណុចខុសគ្នារវាងសកម្មភាពនៅក្នុងការប្រព្រឹត្តនៅក្នុងបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្ត។

**-បទល្មើសឆបោក** : រូបភាពនៅក្នុងបទល្មើសឆបោកជាបឋមគឺជាការប្រគល់ទ្រព្យសម្បត្តិ ឬសេវាដែលកើតឡើងដោយកិច្ចសន្យាដែលជាស្ថានភាពស្របច្បាប់។ ម្យ៉ាងវិញទៀត មានការប្រគល់ស្របច្បាប់ តែការធ្វើឡើងពីដំបូងមានការបន្លំ មានការបន្លំពីសំណាក់ជនល្មើស។ ដោយឡែកចំពោះរូបភាពនៃការប្រព្រឹត្តបទល្មើសឆបោកនេះវិញ ជនល្មើសបានប្រើល្បិចកលដោយទុច្ចរិតទៅលើជនរងគ្រោះ ដោយ ៖

- ប្រើឈ្មោះក្លែង
- អះអាងលើឋានៈក្លែង
- រំលោភលើឋានៈពិតប្រាកដ
- ប្រើឧបាយកលទុច្ចរិត។

ម្យ៉ាងវិញទៀត ជនរងគ្រោះបានយល់ព្រមប្រគល់នូវមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ ទៅឱ្យជនល្មើសដោយសារការជឿទុកចិត្តលើឧបាយកលរបស់ជនល្មើស ហេតុដូច្នេះធ្វើឱ្យខូចខាតដល់ជនរងគ្រោះ ឬតតិយជនផ្សេងទៀតនូវ :

-ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ

-ការផ្គត់ផ្គង់សេវា

-ការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬជាការឱ្យរួចពីកាតព្វកិច្ច។

**-ចំពោះបទល្មើសរំលោភលើទំនុកចិត្តវិញ** : រូបភាពនៃអំពើមានការគៃបំបាត់ ប៉ុន្តែគ្មានការបន្លំទេ តែតាម រយៈកិច្ចសន្យាដែលមានការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយនេះ ជនល្មើសបានទទួលនូវទ្រព្យសម្បត្តិ ឬវត្ថុប្រើប្រាស់ជាកំណត់ មានន័យថាជាសិទ្ធិប្រើប្រាស់ជាកំណត់ មានកាតព្វកិច្ចត្រូវបង្ហាញ ឬមានកាតព្វកិច្ចធ្វើអ្វីមួយជាកំណត់។ នៅពេលដែលមានការរំលោភលើកាតព្វកិច្ច ឬសិទ្ធិប្រើប្រាស់ជាកំណត់កើតឡើង នោះបទល្មើសរំលោភលើទំនុកចិត្តក៏ត្រូវបានកើតឡើងផងដែរ។ តាមរយៈការរំលោភលើកាតព្វកិច្ច ឬការរំលោភលើសិទ្ធិប្រើប្រាស់ជាកំណត់នេះ ធ្វើឱ្យខូចខាតប្រយោជន៍របស់ជនរងគ្រោះ។

### ៣.២.២.២ លក្ខណៈនៃអំពើ

ទោះបីជាបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្ត មើលទៅវាហាក់បីដូចជាស្រដៀងគ្នា ប៉ុន្តែក៏វាមានលក្ខណៈខុសគ្នាផងដែរគឺ ៖

**-បទល្មើសឆបោក** : ពីដើមដំបូងមានការបន្លំ ដោយមានការរៀបចំជាសេនារីយោតាំងតែពីដើមមកម្លេះពោលគឺមានការរៀបចំជាគម្រោងច្បាស់លាស់ណាមួយរបស់ជនល្មើសនៅក្នុងការប្រើប្រាស់កលល្បិច ធ្វើយ៉ាងណាឱ្យជនរងគ្រោះជឿទុកចិត្ត ហើយយល់ព្រមប្រគល់នូវមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិទៅឱ្យជនល្មើស។[28]

---

[28] ឯកសារស្តីពីការប្រៀបធៀបបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្តរបស់សាស្ត្រាចារ្យ កៅ សីហា

**-បទល្មើសរំលោភលើទំនុកចិត្ត** : គឺពុំមានការរៀបចំឧបាយកលទុច្ចរិតតាំងពីដំបូងនោះទេ ប៉ុន្តែបន្ទាប់ពីបានធ្វើកិច្ចសន្យាហើយរហូតមកដល់ដំណាក់កាលនៃការអនុវត្តកិច្ចសន្យានេះ គឺជនល្មើសបានរំលោភទៅលើសិទ្ធិប្រើប្រាស់ជាកំណត់ ឬកាតព្វកិច្ចជាកំណត់ ដែលនេះគឺខុសពីគោលបំណងនៃកិច្ចសន្យា។[29]

**៣.២.២.៣ កម្មវត្ថុនៃបទល្មើស**

ជាការពិតណាស់រាល់បទល្មើសនីមួយៗ តែងតែមានកម្មវត្ថុនៅក្នុងការប្រព្រឹត្ត។ ជាក់ស្តែងកម្មវត្ថុនៅក្នុងបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្ត ក៏ត្រូវបានកំណត់ដូចគ្នាផងដែរនៅក្នុងក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៩ ប៉ុន្តែវាមានភាពខុសគ្នាត្រង់ថា កម្មវត្ថុនៅក្នុងបទល្មើសឆបោកមានចំនួនច្រើនជាងចំនួនកម្មវត្ថុនៃបទល្មើសរំលោភលើទំនុកចិត្ត ដោយ ៖

**បទល្មើសឆបោក** : គឺមានកម្មវត្ថុជាច្រើនដូចជា ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ ការផ្តត់ផ្គង់សេវា ការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬជាការឱ្យរួចពីកាតព្វកិច្ច។

**បទល្មើសរំលោភលើទំនុកចិត្ត** : គឺមានកម្មវត្ថុត្រឹមតែ មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយតែប៉ុណ្ណោះ។

**៣.២.៣ ធាតុអត្តនោម័ត**

ធាតុអត្តនោម័ត ( ធាតុចិត្តសាស្ត្រ ) សំដៅចេតនានៅក្នុងការប្រព្រឹត្តបទល្មើសណាមួយ បូករួមទាំងគោលបំណងនៅក្នុងការប្រព្រឹត្តនូវបទល្មើសណាមួយនោះផងដែរ[30]។ ដោយឡែកចំពោះធាតុផ្សំអត្តនោម័តនៅក្នុងបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្តវិញ ចេតនានៅក្នុងការប្រព្រឹត្តបទល្មើសទាំងពីរគឺមានចេតនានៅក្នុងការប្រព្រឹត្តដូចគ្នា ដោយបទល្មើសឆបោក គឺជនល្មើសមានបំណងទុច្ចរិតនៅក្នុងការប្រព្រឹត្តបទល្មើស ក្នុងគោលបំណងដើម្បីទទួលបាននូវផលប្រយោជន៍អ្វីមួយពីជនរងគ្រោះដែលជារូបវន្តបុគ្គល ឬជានីតិបុគ្គល ហើយដែលចេតនាទាំងនោះរួមមាន ចេតនានៅក្នុងការប្រើឈ្មោះក្លែង ចេតនានៅក្នុងការអះអាងទៅលើ ឋានៈក្លែង ចេតនានៅក្នុងរំលោភលើ ឋានៈពិតប្រាកដ ឬដោយប្រើឧបាយកលទុច្ចរិត។ ដោយឡែកចំពោះបទល្មើសរំលោភលើទំនុកចិត្តវិញ ចេតនានៅក្នុងការប្រព្រឹត្តគឺ ជនល្មើសមានបំណងនៅក្នុងការគេចបំបាត់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយពីជនរងគ្រោះ ដើម្បីយកមកធ្វើជារបស់ខ្លួន ឬតតិយជនណាម្នាក់។ យ៉ាងណាមិញបើយើងក្រឡេកទៅមើលចេតនានៅក្នុងការប្រព្រឹត្តបទល្មើសទាំងពីរនេះវិញ គឺមានភាពខុសគ្នា ហើយចំពោះចេតនានេះទៀតសោត គឺយើងផ្តោតសំខាន់ទៅលើចេតនានៅមុនពេលប្រព្រឹត្តបទល្មើស និងចេតនានៅក្នុងពេលប្រព្រឹត្តបទល្មើស។

**-បទល្មើសឆបោក** : ជនល្មើសមានឆន្ទៈ ឬចេតនានៅក្នុងការប្រព្រឹត្តបទល្មើសតាំងតែមុនពេលដែលជនរងគ្រោះបានប្រគល់នូវមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិមកឱ្យខ្លួនម្លេះ។ ក្នុងន័យនេះមានន័យថា ជនល្មើសមានការគិតទុកមុន មានការរៀបចំឧបាយកលទុកជាមុន ដោយប្រើឈ្មោះក្លែងក្តី ដោយប្រើឋានៈក្លែងក្តី ឬដោយរំលោភលើឋានៈពិតប្រាកដក្តី នៅក្នុងការប្រព្រឹត្តនូវបទល្មើសឆបោក ធ្វើយ៉ាងណាឱ្យមានជនរងគ្រោះជឿជាក់លើការឆបោករបស់ខ្លួន ដើម្បីធ្វើឱ្យខូចខាតដល់ប្រយោជន៍របស់ជនរងគ្រោះ។

---

[29] ឯកសារស្តីពីការប្រៀបធៀបបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្តរបស់សាស្ត្រាចារ្យ កៅ សីហា

[30] សៀវភៅនីតិព្រហ្មទណ្ឌទូទៅ របស់លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត

**-បទរំលោភលើទំនុកចិត្ត** ៖ ជនល្មើសមានឆន្ទៈ ឬចេតនានៅក្នុងការប្រព្រឹត្តបទល្មើសនៅក្រោយពេលដែលជនរងគ្រោះបានប្រគល់នូវមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិមកឱ្យខ្លួន។ ដូច្នេះកាលដែលជនល្មើសបានប្រព្រឹត្តរំលោភលើទំនុកចិត្តនេះ គឺមិនបានគិតទុកជាមុននូវកលល្បិចណាមួយនៅក្នុងការគៃបំបាត់ទ្រព្យសម្បត្តិអ្វីមួយពីជនរងគ្រោះទេ ផ្ទុយទៅវិញជនល្មើសមានចេតនានៅក្នុងការគៃបំបាត់នូវចទ្រព្យសម្បត្តិរបស់ជនរងគ្រោះ នៅក្រោយពេលដែលមានការប្រគល់នូវមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយពីសំណាក់ជនរងគ្រោះ ដើម្បីឱ្យជនល្មើសប្រើប្រាស់បណ្តោះអាសន្ន ឬធ្វើការប្រើប្រាស់ជាកំណត់ណាមួយ។

## ៣.៣ ករណីសិក្សា

### ករណីសិក្សាទី ១

**ចន្ថា** និង **តុលា** ជាមិត្តសម្លាញ់នឹងគ្នា ហើយបានរាប់អាននឹងគ្នាជាយូរឆ្នាំមកហើយ។ ពួកគេទុកចិត្តគ្នាណាស់ ហើយតែងតែជួយគ្នាទៅវិញទៅមកនៅពេលមានអាសន្ន។ ថ្ងៃមួយ **ចន្ថា** និង **តុលា** បានដើរលេងជាមួយគ្នា ហើយក្នុងខណៈនោះ ចន្ថា បានខ្ចីយានយន្តរបស់ តុលា ទៅទទួលកូនចេញពីសាលារៀន។ **តុលា** បានយល់ព្រមឱ្យ ដោយប្រាប់ ចន្ថា ថាក្រោយពេលគាត់យកកូនទៅផ្ទះរួច ត្រូវប្រគល់យានយន្តមកវិញ។ **ចន្ថា** យល់ព្រម។ រហូតដល់ពេលល្ងាច **តុលា** មិនឃើញ **ចន្ថា** យកយានយន្តមកឱ្យខ្លួនវិញទេ ។ **តុលា** បានស្វែងយល់អំពីបញ្ហានេះ ក៏បានដឹងថា **ចន្ថា** បានយកយានយន្តរបស់គាត់ទៅលក់សម្រាប់ចាយវាយ និងដោយសារគាត់បានចាញ់ល្បែងខ្លះ នៅក្រោយពេលខ្លួនយកកូនទៅផ្ទះរួច។

**ដំណោះស្រាយ ៖** អង្គហេតុខាងលើនេះ យើងត្រូវពិនិត្យមើលរាល់ធាតុផ្សំទាំងអស់នៃបទល្មើសដូចខាងក្រោម ៖

ធាតុផ្សំទី ១ : ចន្ថា បានគៃបំបាត់ តុលា ដោយ ចន្ថា បានកេងយកចំណេញលើគាត់ ( យានយន្ត ) របស់ តុលា។

ធាតុផ្សំទី ២ : ទ្រព្យរបស់ តុលា គឺយានយន្ត ដែលជាវត្ថុមានតម្លៃ ដែលអាចប្រើប្រាស់ និងចាយវាយបាននោះ។

ធាតុផ្សំទី ៣ : តុលា បានខូច ឬបាត់បង់ផលប្រយោជន៍ដោយសារយានយន្តរបស់ខ្លួនបានបាត់បង់ និងមិនមានយានយន្តប្រើប្រាស់ទៀតឡើយ តាមរយៈអំពើរបស់ ចន្ថា។

ធាតុផ្សំទី ៤ : តុលា ដែលជាម្ចាស់យានយន្តបានប្រគល់យានយន្តឱ្យ ចន្ថា ដោយស្ម័គ្រចិត្ត និងស្របច្បាប់តាមរយៈការឱ្យខ្ចី។

ធាតុផ្សំទី ៥ : ចន្ថា បានយល់ព្រមប្រគល់យានយន្តឱ្យ តុលា វិញក្រោយពេលខ្លួនជូនកូនទៅផ្ទះរួច តែគាត់មិនបានយកយានយន្តមកប្រគល់ឱ្យ តុលា ដែលជាម្ចាស់យានយន្ត តាមលក្ខខណ្ឌ ឬតាមការសន្យានោះ ទេ។

ដោយផ្អែកលើការវិភាគនេះយើងឃើញថា រាល់ធាតុផ្សំទាំងអស់នៃបទល្មើស រំលោភលើទំនុកចិត្ត ត្រូវបានបំពេញ។ ដូច្នេះអំពើខាងលើនេះជាបទល្មើស រំលោភលើទំនុកចិត្ត។

**ករណីសិក្សាទី ២**

កាលពីថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៨ កន្លងទៅ ឈ្មោះ **ល** និងឈ្មោះ **ខ** បានអះអាងថាខ្លួនជាអ្នករត់ការធ្វើឈ្មោះមន្ត្រីនគរបាល ហើយបានណាត់ឈ្មោះ **រ** ដែលជាជនរងគ្រោះឱ្យទៅជួបនៅភោជនីយដ្ឋានមួយកន្លែង ដើម្បីនិយាយធានារត់ការធ្វើជាមន្ត្រីនគរបាល ក្នុងតម្លៃ ២០.០០០ ដុល្លារ។ បន្ទាប់ពីនិយាយត្រូវគ្នាគ្រប់លក្ខខណ្ឌរួចមក ឈ្មោះ **ខ** បានឱ្យឈ្មោះ ល ទៅទទួលប្រាក់ពី រ ចំនួន ១០.០០០ ដុល្លារ។ លុះដល់ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៩ ឈ្មោះ **ខ** បានឱ្យ រ យកប្រាក់សុទ្ធចំនួន ៥.០០០ ដុល្លារ និងបានតម្រូវឱ្យ រ តម្កល់សៃកមួយសន្លឹកទៀតដែលមានតម្លៃ ៥.០០០ ដុល្លារ មកឱ្យខ្លួនដើម្បីគ្រប់ចំនួន ២០.០០០ ដុល្លារដែលបានព្រមព្រៀងគ្នាកន្លងមក។

ក្រោយពីបានប្រគល់ប្រាក់គ្រប់ចំនួនរួចមក **រ** បានទន្ទឹងរងចាំអស់រយៈពេល ៣ ខែ តែមិនឃើញឈ្មោះរបស់ខ្លួនធ្លាក់មកសោះ ។ រហូតមានការសង្ស័យ ក្រោយមកទើបដឹងថាជនទាំងពីរអ្នកនោះមិនមែនជាមន្ត្រីនគរបាលនោះទេ ហើយថែមទាំងបានយកប្រាក់ដែលខ្លួនបានប្រគល់ឱ្យនោះ រត់ទៅបាត់។

**ដំណោះស្រាយ** ៖ នៅក្នុងករណីនេះ យើងនឹងធ្វើការសិក្សាទៅលើធាតុផ្សំដូចខាងក្រោម ៖

ធាតុផ្សំទី ១ : **ខ** និង **ល** បានបន្លំចំពោះ **រ** ដើម្បីទទួលបានប្រាក់ចំនួន ២០.០០០ ដុល្លារ។

ធាតុផ្សំទី ២ : **ខ** និង **ល** បានប្រើឈ្មោះក្លែង និងអះអាងទៅលើឋានៈជាមន្ត្រីនគរបាលដើម្បីរត់ការ ឱ្យ **រ** ធ្វើជាមន្ត្រី។

ធាតុផ្សំទី ៣ : **ខ** និង **ល** បានប្រើឧបាយកលទុច្ចរិត បន្លំយកប្រាក់ពី **រ** ដើម្បីឱ្យ **រ** បាត់បង់ផលប្រយោជន៍ តាម រយៈអំពើរបស់ខ្លួន។

ធាតុផ្សំទី ៤ : **រ** បានប្រគល់ប្រាក់ចំនួន ២០.០០០ ដុល្លារ ទៅឱ្យ **ខ** និង **ល** ដោយទុកចិត្ត។

ផ្អែកលើការវិភាគនេះយើងឃើញថា រាល់ធាតុផ្សំទាំងអស់នៃបទល្មើសឆបោក ត្រូវបានបំពេញ។ ដូច្នេះ អំពើខាងលើនេះ ជាបទល្មើស ឆបោក។

**ករណីសិក្សាទី ៣**

កាលពីឆ្នាំ ២០១០ ឈ្មោះ **ច** បានធ្វើជាមេតុងទីន ចំនួន បី ក្បាល ដែលក្បាលទី១ មានហ៊ុន ១០ ដុល្លារ កូន ៨០ នាក់ ក្បាលទី ២ មានភាគហ៊ុនចំនួន ១០ ដុល្លារ កូន ៧៦ នាក់ និងក្បាលទី ៣ មានភាគហ៊ុន មួយហ៊ុន ១០ ម៉ឺនរៀល កូន ៣០០ នាក់។ ដោយការលេងបានប្រមាណរយៈពេលជាង ៨០% នៃការដេញតុងទីន ឈ្មោះ **ច** គ្មានប្រាក់សងកូនដោយសារតែ **ច** យកប្រាក់ទាំងនោះទៅភ្នាល់ល្បែងចាញ់អស់ ដោយត្រូវជនរងគ្រោះប្ដឹងទៅនគរបាលចាប់បញ្ជូនខ្លួនទៅកាត់ទោសនៅតុលាការខេត្តព្រៃកនៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០។

ក្នុងរឿងក្ដីនេះ ជនរងគ្រោះមានចំនួនបីនាក់ ដែលបានដាក់ពាក្យបណ្ដឹងមកស្នងការនគរបាលខេត្តព្រៃក និងព្រះរាជអាជ្ញាអមសាលាដំបូងខេត្តព្រៃក មាន ៖

១. ឈ្មោះ **ក** បានប្ដឹងតាមពាក្យបណ្ដឹង ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១០ មកស្នងការនគរបាលខេត្តព្រៃក។ ជនរងគ្រោះនេះ បានត្រូវមេតុងទីនឆបោកប្រាក់អស់ចំនួន ១៦០០ ដុល្លារ និងប្រាក់រៀល ២.៨០០.០០០ រៀល ( ពីរលាន ប្រាំបីសែនរៀល )។

២. ជនរងគ្រោះឈ្មោះ **ស** បានដាក់ពាក្យបណ្តឹងនៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១០ មកស្នងការនគរបាលខេត្តព្រៃក។ ជនរងគ្រោះនេះ បានត្រូវមេតុងទីនឆបោកប្រាក់អស់ចំនួន ៥៨៨ ដុល្លារ និងប្រាក់រៀល ៣.៤៧២.០០០ រៀល។

៣. ជនរងគ្រោះឈ្មោះ **ល** បានដាក់ពាក្យបណ្តឹងនៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១០ មកស្នងការនគរបាលខេត្តព្រៃក។ ជនរងគ្រោះនេះ បានត្រូវមេតុងទីនឆបោកប្រាក់អស់ចំនួន ៣៣០០ ដុល្លារ និងប្រាក់រៀល ២.៨៦០.០០០ រៀល។

**ដំណោះស្រាយ**

១. ធាតុផ្សំនីត្យានុកូល

ដោយយោងទៅតាមមាត្រា ៣៩១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩ បានកំណត់ថា អំពើរំលោភលើទំនុកចិត្ត គឺជាអំពើគៃបំបាត់ មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ នាំឱ្យខូចប្រយោជន៍អ្នកដទៃ ប្រព្រឹត្តដោយបុគ្គលណាម្នាក់ ដែលគេបានប្រគល់ឱ្យបុគ្គលនោះ ហើយបុគ្គលនោះបានយល់ព្រម ដោយមានភារកិច្ចប្រគល់សងវិញ បង្ហាញ ឬយកមូនិធិ តម្លៃ ឬទ្រព្យសម្បត្តិនោះ ទៅធ្វើការប្រើប្រាស់ជាកំណត់។

បទល្មើសរំលោភលើទំនុកចិត្តនេះត្រូវផ្តន្ទាទោសតាមមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩។ ដោយឡែកចំពោះការផ្តន្ទាទោសនេះវិញគឺដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល។

២. ធាតុផ្សំសត្យានុម័ត ឬធាតុសម្ភារៈ

-មានសកម្មភាពគៃបំបាត់ប្រាក់របស់កូនតុងទីន

-មានការប្រគល់មូលនិធិ ប្រាក់កាក ទ្រព្យសម្ភារៈមានតម្លៃ ដែលជាការរៀបចំមធ្យោបាយបន្លំ

-មានការខូចខាត ព្យសនកម្ម

៣. ធាតុផ្សំអត្តនោម័ត

ចារីដែលប្រព្រឹត្តអំពើឆបោកនេះ គឺជាបទល្មើសដោយចេតនា ដែលមានគៃបំបាត់ប្រាក់របស់ជនរងគ្រោះដែលជាកូនតុងទីន នៅពេលកូនបានប្រគល់ប្រាក់ទៅឱ្យជនល្មើស។

ផ្អែកលើការវិភាគនេះយើងឃើញថា រាល់ធាតុផ្សំទាំងអស់នៃបទល្មើសរំលោភលើទំនុកចិត្ត ត្រូវបានបំពេញ។ ដូច្នេះអំពើខាងលើនេះ ជាបទល្មើស រំលោភលើទំនុកចិត្ត។

**ករណីសិក្សាទី ៤**

នៅក្នុងរឿងតុងទីនដដែល ប៉ុន្តែបើ ឈ្មោះ ច បានជំពាក់ប្រាក់ធនាគារដោយគ្មានលទ្ធភាពបង់ ហើយបន្ទាប់មក ក៏បែកគំនិតដើរបបួលអ្នកភូមិឱ្យមកលេងតុងទីន ដោយតាំងខ្លួនជាមេតុងទីន ហើយមានអ្នកភូមិជាច្រើនបានព្រមលេង ដោយគិតថា ច ជាអ្នកភូមិជាមួយគ្នា។ ច បានធ្វើជាមេតុងទីន ចំនួនបី ក្បាល ដែលក្បាលទី១ មានហ៊ុន ១០ ដុល្លារ កូន ៨០ នាក់ ក្បាលទី ២ មានភាគហ៊ុនចំនួន ១០ ដុល្លារ កូន ៧៦ នាក់ និងក្បាលទី ៣ មានភាគហ៊ុន មួយហ៊ុន ១០ ម៉ឺនរៀល កូន ៣០០ នាក់។ ដោយការលេងបានប្រមាណរយៈពេលជាង ៨០% នៃការដេញតុងទីន ឈ្មោះ ច បានយកប្រាក់នោះទៅសងធនាគារ រួចរត់គេចខ្លួនបាត់ទៅ។

ដំណោះស្រាយ ៖

-ធាតុផ្សំទី ១ : ច ត្រូវបានទុកចិត្តពីអ្នកភូមិ ហើយព្រមលេងតុងទីនជាមួយ។

-ធាតុផ្សំទី ២ : ច ជាអ្នកដើរប្រមូលលុយពីកូនតុងទីន ហើយអ្នកភូមិដែលជាកូនតុងទីនបានប្រគល់លុយទៅ ច តាមកាតព្វកិច្ច។

-ធាតុផ្សំទី ៣ : ច បានប្រើឧបាយកលទុច្ចរិត ដើម្បីយកប្រាក់ពីការលេងតុងទីននោះ ទៅសងធនាគារ

-ធាតុផ្សំទី ៤ : មានចេតនាបន្លំយកប្រាក់ទាំងនោះដែលនាំឱ្យបាត់បង់ផលប្រយោជន៍របស់កូនតុង ទីន។

ដោយផ្អែកតាមការវិភាគនៃធាតុផ្សំខាងលើ ធាតុផ្សំនៃបទល្មើសឆបោកត្រូវបានបំពេញ ដូច្នេះបទល្មើសនេះគឺជាបទល្មើសឆបោក។

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សា និងឆ្លងកាត់តាមរយៈ ការបកស្រាយលើបទល្មើសទាំងពីរខាងលើនេះ យើងសង្កេតឃើញថាវាចំណុចដូចគ្នាច្រើន ហើយក៏វាមានចំណុចខុសគ្នាច្រើនផងដែរ។ ហើយបើតាមស្ថានភាពនៃការអនុវត្តក្នុងពេលបច្ចុប្បន្នរបស់មន្ត្រីនគរបាលខ្លះ ក៏ហាក់មានការយល់ច្រឡំភាន់ទៅលើប្រភេទនៃបទល្មើសទាំងពីរនេះ ក៏ព្រោះតែដូច្នោះហើយ ទើបបានជាតម្រូវឲ្យយើងត្រូវពិនិត្យ និងសិក្សាឈ្វេងយល់ទៅលើផ្នែកខុសគ្នា ឬដូចគ្នារវាងបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្តនេះ តាមរយៈខ្លឹមសារនៃបទបញ្ញត្តិ នៅក្នុងក្រមព្រហ្មទណ្ឌដែលឆ្លុះបញ្ចាំងឱ្យឃើញពីគោលការណ៍ដែលជាធាតុផ្សំច្បាស់លាស់នៃបទល្មើសនោះ ដើម្បីធ្វើការប្រៀបធៀបគ្នា។

បើយើងពិនិត្យមើលឡើងវិញ លើបទល្មើសទាំងពីរ ដែលបទល្មើសឆបោក មានចែងក្នុងមាត្រា ៣៧៧ និងបទល្មើសរំលោភលើទំនុកចិត្តមានចែងក្នុងមាត្រា៣៩១ ដែលយើងនឹងលើកយកមកធ្វើការប្រៀបធៀបជាដំបូងនោះលក្ខណៈដូចគ្នា។ ជាក់ស្តែងក្នុង បើយើងពិនិត្យទៅលើធាតុនីត្យានុកូល វាគឺជាបទប្បញ្ញត្តិមួយដែលក្រមព្រហ្មទណ្ឌបានកំណត់ថាវាជាបទល្មើស ហើយដែលត្រូវផ្តន្ទាទោសដូចគ្នា។ មែនទែនទៅបទល្មើសទាំងពីរនេះគឺហាក់នៅមិនឆ្ងាយពីគ្នាប៉ុន្មានឡើយ គឺវាត្រូវបាននីតិករចងក្រងឲ្យនៅក្នុងគន្ថីតែមួយ គឺស្ថិតក្នុងគន្ថីទី៣ ស្តីអំពី បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ។ ព្រោះបទល្មើសទាំងពីរនេះមានជាប់ទាក់ទងនឹងទ្រព្យសម្បត្តិដូចគ្នា ហើយធ្វើឱ្យប៉ះពាល់ដល់កម្មសិទ្ធិរបស់បុគ្គល រួមមានទ្រព្យសម្បត្តិ ឬវត្ថុមានតម្លៃផ្សេងៗដូចគ្នាជាដើម។ ម្យ៉ាងទៀតចំពោះការចែងក្នុងមាតិកាវិញ បទល្មើសទាំងពីរ គឺមានចរិតលក្ខណៈ ត្រូវបានចែងកំណត់ជាមួយគ្នា ដែលជាប់ទាក់ទងនឹងការយកទ្រព្យសម្បត្តិអ្នកដទៃមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនដោយទុច្ចរិត។ ហើយនៅក្នុងប្រធាននៃបទល្មើសវិញ គឺបានកំណត់ដល់ស្ថានភាពដែលប្រព្រឹត្តឡើងដោយរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបង្កឡើងក្នុងន័យទទួលបាននូវផលប្រយោជន៍ណាមួយដោយទុច្ចរិត។ ចំណែកជនល្មើសវិញ គឺមានចេតនាទុច្ចរិត ធ្វើការបំភាន់ ឬក្លែងនូវឋានៈ ដើម្បីទទួលបាននូវ មូនិធិ តម្លៃ សេវា ឬទ្រព្យសម្បត្តិអ្វីមួយ ជាការគៃបន្លំ ក្នុងបំណងធ្វើឱ្យខូចប្រយោជន៍ដល់ម្ចាស់កម្ម។ ចំណាត់ថ្នាក់នៃបទល្មើស( បទល្មើសជាបទមជ្ឈិម មានរយៈពេលលើសពី៦ថ្ងៃ ដល់ក្រោម ឬស្មើ៥ឆ្នាំ)។ អាជ្ញាយុកាលនៃទោស និងបទល្មើស បទមជ្ឈិមមានរយៈពេល៥ឆ្នាំ។ ការប៉ុនប៉ង ក្នុងបទល្មើសទាំងពីរគឺមានទោសដូចគ្នា។

ផ្ទុយទៅវិញ ចំពោះបទល្មើសទាំងពីរ បើយើងដាកពិនិត្យមើលទៅ ធាតុនីត្យានុកូល នៃបទល្មើសវិញ គឺមានភាពខុសគ្នាយ៉ាងច្បាស់ សូម្បីតែការប្រើប្រាស់ពាក្យពេចន៍ បូករួមទាំងអត្ថន័យក្នុងបទល្មើសផងដែរ។ មិនតែប៉ុណ្ណោះ ក៏មានការចែងដាច់ដោយឡែកពីគ្នានៃជំពូកផងដែរ ដោយបទល្មើសឆបោក ចែងក្នុងជំពូកទី២ ចំណែកបទល្មើសរំលោភលើទំនុកកចិត្តវិញ គឺស្ថិតក្នុងជំពូកទី៣ នៃក្រមព្រហ្មទណ្ឌ។ បើនិយាយពីស្ថានទម្ងន់ទោស ដោយក្នុងបទឆបោក បានកំណត់យ៉ាងជាក់លាក់ ចំនួនពីរ គឺស្ថានទម្ងន់ទោសដែលទាក់ទងនឹងជនរងគ្រោះ ត្រង់មាត្រា ៣៧៩ និងស្ថានទម្ងន់ទោសផ្សេងទៀត ត្រង់មាត្រា៣៨០ ចំណែកបទរំលោភលើទំនុកកចិត្ត គឺបានកំណត់ក្នុងមាត្រា៣៩៤ បញ្ញត្តិពីស្ថានទម្ងន់ទោសទាក់ទងនឹង

ជនល្មើស។ ចំណុចដែលគួរកត់សម្គាល់ ត្រង់ទោសបន្ថែមវិញ គឺបទល្មើសឆបោក មានរហូតដល់១៣ ចំណុច រីឯបទរំលោភលើទំនុកចិត្តមានត្រឹមតែ១០ប៉ុណ្ណោះ។ បើពិនិត្យទៅមើលធាតុសត្យានុម័តវិញ រូបភាពនៃអំពើរវាងបទល្មើសទាំងពីរ បទឆបោក គឺជនល្មើសធ្វើការបន្លំ ក្នុងគោលបំណងទុច្ចរិត ចំណែកបទរំលោភលើទំនុកចិត្ត គឺមានលក្ខណៈជាការគៃបំបាត់ ឬរំលោភលើកិច្ចសន្យា។ ហើយចំពោះធាតុអត្តនោម័តវិញ ក្នុងបទឆបោក ជនល្មើសមានចេតនាប្រព្រឹត្តបទល្មើសមុនការប្រគល់វត្ថុ ឯបទរំលោភលើទំនុកចិត្ត គឺមានចេតនាប្រព្រឹត្តកើតក្រោយការប្រគល់ កម្មវត្ថុនៃបទល្មើសមកឱ្យខ្លួន។

បន្ទាប់ពីបានធ្វើសេចក្តីសន្និដ្ឋានរួចមក យើងខ្ញុំសូមបញ្ចេញនូវមតិយោបល់ខ្លះ ដែលពាក់ព័ន្ធទៅនឹងចំណុចខ្វះខាតមួយចំនួននៃបទល្មើសទាំងពីរខាងលើនេះ ដែលនឹងលើកឡើងជាអនុសាសន៍ក្នុងចំណុចបន្ទាប់នេះ។

## អនុសាសន៍

ឆ្លងតាមការបកស្រាយដោយប្រៀបធៀបនូវបទល្មើសឆបោក និងរំលោភលើទំនុកចិត្តតាំងពីខាងដើមរួចមកយើងឃើញថា មានចំណុចមួយចំនួនបានផ្តល់នូវគុណសម្បត្តិ ហើយចំណែកចំណុចមួយចំនួនទៀតក៏បានផ្តល់នូវគុណវិបត្តិផងដែរ។ ទោះយ៉ាង បទល្មើសទាំងពីរនេះគឺមានភាពស្រដៀងគ្នាយ៉ាងខ្លាំងដែលបានធ្វើឱ្យមហាជន ក៏ដូចជាអ្នកសិក្សាផ្នែកច្បាប់មួយចំនួនមានការភាន់ច្រឡំ។ ដោយសម្អាងលើមូលហេតុមួយនេះហើយបានជាយើងខ្ញុំសូមផ្តល់នូវមតិយោបល់មួយចំនួន ដែលស្ថិតនៅក្នុងក្របខណ្ឌដើម្បីស្ថាបនា ការអនុវត្តច្បាប់ឱ្យកាន់តែច្បាស់លាស់ និងឆាប់រហ័ស យើងខ្ញុំសូមលើយកចំណុចមួយចំនួនដូចជា ៖

## ១. បទបញ្ញត្តិនៃច្បាប់

ការចែងកំណត់បទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្ត នៅក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩ គួរតែធ្វើយ៉ាងណាឱ្យមានភាពងាយស្រួលក្នុងការស្វែងយល់នូវរាល់អត្ថន័យដែលបានកំណត់នៅក្នុងបទល្មើសនេះ ដែលអាចឱ្យមហាជនទូទៅ យល់ដឹងអំពីបទល្មើសទាំងពីរ ដូចនឹងអ្នកសិក្សាផ្នែកច្បាប់ដែរ។

## ២. ការអនុវត្តច្បាប់

កាលណាបើមានការស្រពេចស្រពិលនៅក្នុងការកំណត់បទល្មើសហើយ ជាហេតុនាំឱ្យមានការអនុវត្តមិនចំគោលដៅ។ ដូច្នេះមន្ត្រីអនុវត្តច្បាប់គ្រប់រូបគួរគប្បីសិក្សាស្វែងយល់ដោយខ្លួនឯង ឬចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលផ្សេងៗដែលបានរៀបចំដោយក្រសួង ឬស្ថាប័នមួយចំនួនដើម្បីទទួលបាននូវចំណេះដឹងបន្ថែមនៅក្នុងការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ និងមានតម្លាភាព។ ការធ្វើដូចនេះ មិនត្រឹមតែអាចជួយបង្កើនចំនួនអ្នកដែលមានចំណេះដឹងប៉ុណ្ណោះទេ វាថែមទាំងបានធ្វើឱ្យការអនុវត្តច្បាប់នៅក្នុងប្រទេសជាតិយើងកាន់តែប្រសើរថែមមួយកម្រិតទៀត។